# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*លោកតាដំបងដែក បានប្រមូលបុព្វការីជនទាំងអស់មកប្រាប់ខ្ញុំថា "ឯង! កុំនិយាយអីផ្តេសផ្តាស។ ឯង! ត្រូវគិតភាសាខ្មែរឲ្យច្បាស់ សិរីសួស្តី។ ពាក្យ "សិរីសួស្តី" បើសំណួរណាមិនមានសិរីសួស្តីទេ ឯង! មិនត្រូវស្តីរកទេ"។*

**-សាក្សី លោក សាឡុត បាន**

## ផ្នែកទី ១៖ និដ្ឋភាពទូទៅ

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានស្តាប់សក្ខីកម្មរបស់លោក **សាឡុត បាន** ដែលជាអតីតអគ្គលេខាធិការក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ខាងសហព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ និងក្រុមការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** បានតាំងសំណួរដេញដោលទៅកាន់សាក្សីរូបនេះ។[1]

លោក **សាឡុត បាន** ត្រូវបានសួរសំណួរដេញដោលអំពីជីវប្រវត្តិរបស់គាត់ ទំនាក់ទំនងជាមួយលោក **ប៉ុល ពត** ភាពស្និទ្ធស្នាលជាមួយនឹងមេដឹកនាំខ្មែរក្រហមដទៃទៀត និងពីរបៀបនៃការធ្វើសេចក្តីសម្រេចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ សំណួរដេញដោលទាំងនេះ បានផ្តោតជាពិសេសទៅលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ **អៀង សារី** ពាក់ព័ន្ធនឹងការចាប់ខ្លួន និងការឃុំឃាំងបញ្ញវន្តដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ និងបុគ្គលិករបស់ក្រសួងការបរទេសនេះ។ សាក្សីរូបនេះ ក៏បានផ្តល់សក្ខីកម្មផងដែរពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល ការទំនាក់ទំនងគ្នា និងការធ្វើសេចក្តីសម្រេចរបស់ក្រសួរការបរទេស។ គាត់បានផ្តល់សក្ខីកម្មអំពី មន្ទីរ ៨៧០ បឹងត្របែក និងច្រាំងចំរេះ ដែលត្រូវបានសន្និដ្ឋានថាជាកសិដ្ឋានចិញ្ចឹមសត្វ និងមន្ទីរបង្កបង្កើនស្បៀង។[2]

## ផ្នែកទី ២ ៖ សក្ខីកម្មសង្ខេបរបស់លោក សាឡុត បាន

លោក **សាឡុត បាន** (មានរហស្សនាមថា "**សួរ ហុង**" "**និត្យា**" "**សេង លីតា**" "**កាម៉ាទ្បៃ**" ជាយុទ្ធជនចូលនិវត្តន៍ដែលមានអាយុ៦៧ឆ្នាំ។ ឪពុករបស់គាត់គឺជាកសិករ ហើយគាត់ស្ថិតនៅក្នុងវណ្ណៈកសិករ។ ឪពុករបស់គាត់ គឺជាបងប្រុសរបស់ **សាឡុត ស** ដែលហៅថា "**ប៉ុល ពត**" ក៏ប៉ុន្តែគាត់បាននិយាយថា ទំនាក់ទំនងរបស់គាត់ជាប់ខ្សែលោហិតជាមួយនឹងលោក **ប៉ុល ពត** មិនបានជះឥទ្ធិពលអ្វីមកលើឋានៈសង្គមរបស់គាត់ឡើយ។ គាត់ បានចាកចេញពីឪពុកម្តាយរបស់គាត់តាំងពីគាត់មានអាយុ ៧ឆ្នាំ និងបានរួមរស់នៅជាមួយនឹងឪពុកមាជាច្រើន។ កាលគាត់មានអាយុបាន ១៣ឆ្នាំ គាត់បានរស់នៅជាមួយនឹង **ប៉ុល ពត** ដែលស្នាក់នៅក្នុងផ្ទះតែមួយជាមួយនឹងលោក **អៀង សារី** ។ ជាចុងក្រោយ គាត់បានបញ្ជាក់ថា គាត់បានគោរព និងស្រឡាញ់លោក **អៀង សារី** ដូចដែលគាត់បានធ្វើចំពោះឪពុកមារបស់គាត់ដែរ។

យោងតាមការសិក្សារបស់គាត់ គាត់បានសិក្សាប្រហែល១០ឆ្នាំនៅក្នុងសាលា។ គាត់មិនបានបន្តការសិក្សានៅថ្នាក់សាកលវិទ្យាល័យទេ ហើយបានប្រឡងធ្លាក់ថ្នាក់ឌីប្លូម៉ា (ថ្នាក់មធ្យមសិក្សា)។ មុនចលនាបដិវត្តន៍បានចាប់ផ្តើម គាត់បានធាក់ស៊ីក្លូនៅពេលយប់ និងធ្វើការជាកម្មករសំណង់។ សាក្សីរូបនេះ បានផ្តល់សក្ខីកម្មថា គាត់បានរត់ចេញពីទីក្រុងភ្នំពេញ ទៅកាន់ខេត្តក្រចេះ ដោយសារមូលហេតុតែរដ្ឋាភិបាល **លន់ នល់** បានចោទប្រកាន់គាត់ថាជាជនក្បត់។ បន្ទាប់ពីពេលនោះមក គាត់បានរស់នៅក្នុងខេត្តក្រចេះពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៦៧។ នៅទីនោះ គាត់បានជួបនឹងលោក **សឿ វ៉ាស៊ី** (ហៅ **ឌឿន**)។[3]

នៅក្នុងឆ្នាំ១៩៦៨ ឬក៏១៩៦៩ គាត់បានចូលរួមជាមួយនឹង **ប៉ុល ពត** នៅខេត្តរតនៈគិរី និងបានក្លាយជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា ជាមួយនឹងគំនិតនៃការរំដោះប្រទេសជាតិឲ្យចេញពីការត្រួតត្រារបស់ចក្រពត្តិអាមេរិកកាំង។ យោងតាមសម្តីរបស់គាត់ ពុំមានលក្ខខណ្ឌតម្រូវច្បាស់លាស់ណាមួយដើម្បីក្លាយជាសមាជិករបស់បក្សឡើយ។

តួនាទីរបស់គាត់នៅក្នុងចលនានេះមិនសូវជាទៀងទាត់នោះឡើយ។ សាក្សីរូបនេះ បានពន្យល់ថានៅចន្លោះឆ្នាំ១៩៧០ និង១៩៧៥ គាត់បានធ្វើជាកងការពារឲ្យ **ប៉ុល ពត** នៅក្នុងអំឡុងពេលដែលគាត់បានគ្រប់គ្រងសមាជិកដែលមានគ្នា៣០នាក់ទៀតផង។ នៅក្នុងតួនាទីជាកងការពារ គាត់បាននៅជិតដិត និងបានការពារ **ប៉ុល ពត** និង **អៀង សារី** ។ គាត់ក៏ជាអ្នកនាំសារ និងជាចុងភៅចម្អិនម្ហូបផងដែរ។ គាត់បានមកដល់ទីក្រុងភ្នំពេញក្នុអំឡុងខែឧសភា ឆ្នាំ១៩៧៥ ដែលនៅទីនោះ លោក **ឈឹម សំអោក** ហៅ "**ប៉ង់**" បានចាត់តាំងឲ្យគាត់ធ្វើជាអ្នកបោសសម្អាតនៅក្នុងក្រសួងការពារជាតិ។ នៅពេលដែលលោក **អៀង សារី** បានវិលត្រឡប់មកពីបរទេសវិញ គាត់បានតែងតាំងលោក **សាឡុត បាន** ជាអគ្គលេខាធិការក្រសួងការបរទេស ដែលនៅពេលនោះគាត់មានអាយុត្រឹមតែ២៨ឆ្នាំប៉ុណ្ណោះ។ សាក្សីបាននិយាយថា លោក **អៀង សារី** បានតែងតាំងគាត់ឲ្យមានឋានៈនេះ ក៏ដោយសារតែក្តីស្រឡាញ់របស់លោក **អៀង សារី** ចំពោះគាត់ និងសម្រាប់ភាពស្មោះត្រង់របស់គាត់ដែលមាន។ នៅក្នុងឆ្នាំ ១៩៧៧ គាត់ក៏បានគ្រប់គ្រងនៅប្រាំងចំរេះ។

## ក.  ការិយាល័យ ៨៧០

ការសួរសំណួរដេញដោលពីសំណាក់គ្រប់ភាគីទាំងអស់ស្តីពីការិយាល័យ ៨៧០ ពេញមួយសប្តាហ៍នេះ លោក **សាឡុត បាន** បានអះអាងម្តងហើយម្តងទៀតថា ការិយាល័យ ៨៧០ ដែលសំដៅផងដែរថាជាការិយាល័យរបស់ថ្នាក់ដឹកនាំ ឬការិយាល័យអង្គការ បានផ្លាស់ប្តូរទីតាំងជាច្រើនដង គឺដោយសារតែមជ្ឈដ្ឋានវឹកវរបានកើតឡើងនៅពេលនោះ។ នៅមុនពេល "រំដោះ" ទីក្រុងភ្នំពេញ **សាឡុត បាន** បាននិយាយថា ការិយាល័យ ៨៧០ ត្រូវបានស្គាល់ថាជា ការិយាល័យ ១០០ ហើយមានទីតាំងនៅក្នុងខេត្តរតនៈគិរី។ គាត់មានរម្លឹកថា បក្សមិនសូវបានធ្វើកិច្ចប្រជុំជាញឹកញាប់នៅពេលដែលការិយាល័យនោះស្ថិតនៅក្នុងខេត្តរតនៈគិរីឡើយ។[4] នៅក្នុងឆ្នាំ១៩៦៧ ឬដើមឆ្នាំ១៩៦៨ សាក្សីរូបនេះបាននិយាយថា គាត់បានឃើញ **ប៉ង់** កំពុងធ្វើការនៅទីនោះ។ ពីរ ឬបីឆ្នាំបន្ទាប់មក ក្នុងឆ្នាំ១៩៧០ គាត់បានរម្លឹកប្រាប់ពីការជួបគ្នាជាមួយនឹងឪពុកមារបស់គាត់ លោក **ប៉ុល ពត** និងប្រពន្ធរបស់លោក **ប៉ុល ពត** លោក **សុន សេន** លោក **អៀង សារី** អ្នកស្រី **អៀង ធីរិទ្ធ** និងលោក **នួន ជា** នៅក្នុងខេត្តរតនៈគិរី។ **សាឡុត បាន** បានបញ្ជាក់ថា នៅពេលនោះ គាត់មិនបានឃើញលោក **ខៀវ សំផន** ឡើយ។

**នៅស្ទឹងជីនិត ក្បែរខេត្តកំពង់ធំ និងកំពង់ចាម៖** តាមសាក្សីបានឲ្យដឹងថា ការិយាល័យមជ្ឈិម បានផ្លាស់ប្តូរទីតាំងពីខេត្តរតនៈគិរី ទៅស្ទឹងជីនិត នៅក្បែរខេត្តកំពង់ធំ និងកំពង់ចាម បន្ទាប់ពីមាន **រដ្ឋប្រហារ លន់ នល់** បានកើតឡើងក្នុងឆ្នាំ១៩៧០។ គាត់បាននិយាយថា **ប៉ុល ពត** និង **នួន ជា** បានស្នាក់នៅក្នុងតំបន់នេះនៅក្នុងអំឡុងពេលនោះ។ មានការិយាល័យសំខាន់ចំនួនពីរស្ថិតនៅក្រោមការិយាល័យមជ្ឈិម មានដូចជា៖ ការិយាល័យ ស-២១ និងការិយាល័យ ស-៧០។ ការិយាល័យ ស-២១ មានទីតាំងតាមបណ្តោយស្ទឹងជីនិត និងជាកន្លែងសម្រាកសម្រាប់ថ្នាក់ដឹកនាំបក្ស។ រីឯការិយាល័យ ស-៧០ វិញ ដែលមានចម្ងាយផ្លូវពីស-២១ ដោយត្រូវដើរមួយថ្ងៃនោះ គឺជាកន្លែងសម្រាប់វគ្គអប់រំសិក្សា។

**នៅឧដុង្គ ខេត្តកំពង់ស្ពឺ៖** តាមឲ្យដឹងមក ការិយាល័យមជ្ឈិម បានផ្លាស់ប្តូរទីតាំងពីស្ទឹងជីនិតមកឧដុង្គ ក្នុងខេត្តកំពង់ស្ពឺ។ **ប៉ុល ពត** ជាអ្នកត្រួតត្រាលើការិយាល័យនេះនៅឧដុង្គ ហើយគណៈភូមិភាគត្រូវបានហៅមកប្រជុំតាមការបញ្ជារបស់គាត់។ កិច្ចប្រជុំទាំងនេះ នៅតូចនៅឡើយ ហើយមានតែគ្នាពីរនាក់ ឬជាលក្ខណៈបុគ្គលតែប៉ុណ្ណោះ។ នៅពេលដែលលោក **សាឡុត បាន** បានបដិសេធថាគាត់មិនបានដឹងពីកម្មវត្ថុនៃកិច្ចប្រជុំទាំងនេះ គាត់បានទាយថា ថ្នាក់ដឹកនាំបក្ស អាចកំពុងរៀបចំផែនការដើម្បីវាយទីក្រុងភ្នំពេញនៅពេលនោះ។

**នៅឃុំពាម ខេត្តកំពង់ឆ្នាំង៖** សាក្សីបានរម្លឹកថា វាមិនបានប្រើពេលយូរណាស់ណាទេមុនពេលដែលការិយាល័យមជ្ឈិមបានផ្លាស់មកឃុំពាម ក្នុងខេត្តកំពង់ឆ្នាំង។ គាត់បានពិពណ៌នាពីការិយាល័យនេះ ដែលបានដឹកនាំដោយលោក **ប៉ុល ពត** ដូចជារោងដោលតូចមួយក្នុងព្រៃ។ **សាឡុត បាន** បាននិយាយថា គាត់បានឃើញលោក **នួន ជា** នៅក្នុងតំបន់នោះ ក៏ប៉ុន្តែគាត់មិនបាននិយាយអ្វីទៀតឡើយ។ គាត់ ក៏បានចងចាំផងដែរពីកិច្ចសហការជាមួយនឹងលោក **ខៀវ សំផន** នៅខណៈពេលដែលកំពុងធ្វើការកែច្នៃគ្រាប់រំសេវ។ ទោះបីជាយ៉ាងនេះក្តី គាត់បានអះអាងថា លោក **ខៀវ សំផន** មិនបានគ្រប់គ្រងចាត់ចែងកិច្ចការយោធាឡើយ ក៏ប៉ុន្តែគ្រាន់តែបានជួយគាត់លើកិច្ចការនេះ ដោយសារតែគាត់មិនសូវចេះអានអក្សរឡើយ។ **សាឡុត បាន** បាននិយាយពីរបៀបនៃការរៀបចំកិច្ចប្រជុំនៅក្នុងការិយាល័យមជ្ឈិម ក៏ប៉ុន្តែ គាត់មិនបានដឹងពីរបៀបវារៈរបស់កិច្ច

ប្រជុំឡើយ។ ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ថ្នាក់ដឹកនាំបក្ស បានទុកឲ្យគាត់នៅម្នាក់ឯងក្នុងការការពាររោងដោលនោះ ដែលជាការិយាល័យមជ្ឈិម និងគ្រាប់រំសេវដែលទុកនៅទីនោះ។

**នៅទីក្រុងភ្នំពេញ៖** បន្ទាប់ពីការជួលរំលំទីក្រុងភ្នំពេញមក ការិយាល័យ ៨៧០ បានប្តូរទីតាំងជាថ្មីម្តងទៀតទៅកាន់ ក-១ នៅទល់មុខមាត់ទន្លេក្នុងទីក្រុងភ្នំពេញ។ តាមឲ្យដឹងមក **ប៉ង់** ដែលជាប្រធានការិយាល័យ ៨៧០ មានអំណាចក្នុងការគ្រប់គ្រងគ្រប់ក្រសួងទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **សាឡុត បាន** បានពន្យល់ថា ក-១ ត្រូវបានបែងចែកជាការិយាល័យខុសៗគ្នាជាច្រើន រួមទាំងការិយាល័យចល័ត បានហៅថា ក-២ ដែលគាត់បានជឿជាក់ថា ត្រូវបានដឹកនាំដោយ **ឌឿន** ។[5] នៅពេលដែល **ឌឿន** បានបាត់ខ្លួន លោក **ខៀវ សំផន** ជាអ្នកមើលការខុសត្រូវក្នុងការចាត់ចែងបុគ្គលិក ក-២ នេះ។[6]

យោងតាមសាក្សី **ប៉ង់** បានបាត់ខ្លួនភ្លាមៗមុនពេលដែលវៀតណាម បានមកដល់ (នៅក្នុងខែមករា ឆ្នាំ១៩៧៩)។ នៅពេលដែលគាត់បាននិយាយថា គាត់មិនបានដឹងថានរណាបានជំនួសកន្លែងរបស់ **ប៉ង់** ឲ្យប្រាកដនោះឡើយ គាត់បានបញ្ជាក់ថា លោក **ប៉ុល ពត** លោក **នួន ជា** និងមេដឹកនាំដទៃទៀត បានប្រើប្រាស់អំណាចក្នុងការិយាល័យ៨៧០ នេះ។

## ខ. ក្រសួងការបរទេស

**សាឡុត បាន** បានផ្តល់សក្ខីកម្មថា គាត់បានឡើងឋានៈពីអ្នកបោសសំអាតមកជាអគ្គលេខាធិការក្រសួងការបរទេស ពេលក្រសួងនេះចាប់ផ្តើមដំណើរការ នៅពេលដែលលោក **អៀង សារី** បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ គាត់បានសូមទទូចប្រាប់ថា តួនាទីរបស់គាត់ គ្រាន់តែមានឋានៈតែគ្មានអំណាចអ្វីឡើយ ពីព្រោះគាត់ជាអ្នកជួយសម្របសម្រួលរវាងក្រុមបញ្ញាជន និងក្រុមកសិករ។ គាត់បានពិពណ៌នាពីតួនាទីរបស់គាត់ដែលទទួលខុសត្រូវលើ "ការងារសតិអារម្មណ៍" និង "ជីវភាព" របស់ប្រជាជនដែលធ្វើការនៅក្នុងក្រសួងការបរទេសតែប៉ុណ្ណោះ។ លោក **សាឡុត បាន** បានពន្យល់ថា ការទទួលខុសត្រូវលើបញ្ហានៃ "ការងារសតិអារម្មណ៍" មានន័យថាគាត់បានធ្វើយ៉ាងណាឲ្យតែបុគ្គលិក "រស់នៅឲ្យមានសីលធម៌ ស្នេហាជាតិត្រឹមត្រូវ ចេះការពារជាតិ កសាងជាតិ"។ គាត់ ក៏បានលើកឡើងផងដែរពីការរស់នៅដោយគោរពតាមសីលធម៌១២ប្រការរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីកសាងស្មារតីស្អាតស្អំ។ លោក **អៀង សារី** បានប្រាប់គាត់ថា តួនាទីចម្បងរបស់គាត់នោះ គឺមើលការខុសត្រូវធ្វើឲ្យ "បងប្អូនមានឯកភាពគ្នា"។ សាក្សីរូបនេះ បានសង្កត់ធ្ងន់ម្តងហើយម្តងទៀតថា គាត់ត្រូវបានកម្រិតត្រឹមតែមើលដំណើរការប្រព្រឹត្តទៅរបស់ក្រសួងតែប៉ុណ្ណោះ។ គាត់មិនបានមានការទទួលខុសត្រូវណាមួយលើ "បញ្ញាជន" ទាំងនៅក្នុង ឬខាងក្រៅក្រសួងការបរទេស ដូចតួនាទីទទួលខុសត្រូវរបស់លោក **អៀង សារី** នោះទេ។

គាត់បានសារភាពថា គាត់បានទទួលខុសត្រូវលើកិច្ចការប្រចាំថ្ងៃរបស់ក្រសួងការបរទេស នៅពេលដែលលោក **អៀង សារី** មានបេសកកម្មទៅខាងក្រៅប្រទេស ក៏ប៉ុន្តែគាត់បានសង្កត់បញ្ជាក់ថា គាត់មិនបានមានអំណាចសម្រេចលើបញ្ហាណាមួយឡើយ។ គាត់ ក៏បានផ្តល់សក្ខីកម្មផងដែរថា គាត់បានទទួលទូរស័ព្ទពី **ប៉ង់** ដែលជាអ្នកបានផ្តល់ការណែនាំមានលក្ខណៈសង្ខេប និងមិនច្បាស់លាស់ ទាក់ទងនឹង "ការធ្វើម៉េចកុំឲ្យបែកបាក់គ្នាក្នុង កុំឲ្យមានទំនាស់ និងរក្សាសាមគ្គីភាពឲ្យបាន"។ គាត់ មិនបានឆ្លើយបំភ្លឺបន្ថែមលើប្រធានបទនេះឡើយ។

ជាងនេះទៅទៀត លោក **សាឡុត បាន** បានរាយរាប់ថា គាត់បានហែហមការពារភ្ញៀវ រួមទាំងអ្នកការទូតជាច្រើន ប្រហែលជាពីរដងក្នុងមួយឆ្នាំ ទៅទស្សនានៅតាមទីជនបទ។ ជាពិសេស គាត់បានចងចាំគណៈប្រតិភូពីប្រទេសឡាវ ក្នុងឆ្នាំ១៩៧៧ ដែលត្រូវបានជួយរម្លឹកការចងចាំ ពីសំណាក់សហព្រះរាជអាជ្ញាអន្តរជាតិ លោក **វាំងសង់ វ៉ាយដ៍ ដេស្មាឯល** (Mr. Vincent de Wilde d'ESTMAEL) ដោយបានលើកបង្ហាញគាត់នូវរូបថតចំនួនបីសន្លឹកស្តីពីទស្សនកិច្ចរបស់គណៈប្រតិភូឡាវ។ នៅក្នុងរូបថតទីមួយ សាក្សី បានកំណត់សម្គាល់ថាជា រូបរបស់លោក **អៀង សារី** លោក **នួន ជា** និងលោក **ខៀវ សំផន**។ នៅក្នុងរូបទីពីរ គាត់បានកំណត់សម្គាល់ម្តងទៀតថា ជារូបរបស់លោក **ខៀវ សំផន**។ ហើយនៅពេលដែលមានសំណួរសួរអំពីរូបថតទីបី លោក **សាឡុត បាន** បាននិយាយថា រូបថតនេះ ត្រូវបានថតនៅក្នុងផ្ទះលេខ ១ ហើយបានស្គាល់រូប លោក **អៀង សារី** លោក **ខៀវ សំផន** អ្នកស្រី **អៀង ធីរិទ្ធ** និងលោក **យុន យ៉ាត**[7]។

### *ខ.១. តួនាទី និងរចនាសម្ព័ន្ធនៃក្រសួងការបរទេស*

តាមឲ្យដឹងមក លោក **អៀង សារី** បានក្លាយជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស នៅពេលដែលក្រសួងនេះបានចាប់ដំណើរការនៅក្នុងឆ្នាំ១៩៧៥ ពីរទៅបីខែបន្ទាប់ពី "ការរំដោះ" ទីក្រុងភ្នំពេញបាន។ សាក្សី បានពិពណ៌នាពីក្រសួងការបរទេសថា "មិនទាន់រៀបរយជាការិយាល័យទេ" ហើយអ្នកនៅទីនោះត្រូវបានចាត់ឲ្យធ្វើនេះ ឲ្យធ្វើនោះ តាមតែអ្នកណា "ចេះធ្វើអីល្អមៗទៅក៏ឲ្យទៅធ្វើទៅ"។ សូម្បីតែនៅពេលដែលក្រសួងការបរទេស បានរៀបចំស្រួលបួលហើយក៏ដោយនៅក្នុងឆ្នាំ១៩៧៨ ទៅ១៩៧៩ បុគ្គលិកនៅតែមិនទាន់មានការងារចាត់តាំងណាមួយច្បាស់ការ និងប្រាកដប្រជាឡើយ។

លោក **សាឡុត បាន** បានពន្យល់ថា ក្រសួង ត្រូវបានបែងចែកជាពីរអង្គភាព៖ អង្គភាពទីមួយ ទទួលបន្ទុកដោះស្រាយទៅលើបញ្ញាជន និងអង្គភាពទីពីរ ដោះស្រាយលើបញ្ហាសេដ្ឋកិច្ច ផលិតកម្ម និងជីវភាពរស់នៅ។ នៅខណៈពេលដែលសាក្សីបាននិយាយថា គាត់មិនបានដឹងព័ត៌មានលម្អិតពីបច្ចេកទេស ដែលទាក់ទងនឹងអង្គភាពទទួលបន្ទុកដោះស្រាយជាមួយនឹង "បញ្ញាជន" គាត់អាចធ្វើការបកស្រាយពីអង្គភាពទីពីរ ដែលប្រមូលផ្តុំដោយកសិករដែលមានចំនួនច្រើនជាងបញ្ញាជន ដែលធ្វើការនៅក្នុងក្រសួងនេះ។ គាត់ ក៏បានទទួលស្គាល់ផងដែរថា គាត់ជាអ្នកសម្របសម្រួលមើលការខុសត្រូវរវាងក្រុមបញ្ញាជន និងក្រុមកសិករ ដើម្បីកុំឲ្យពួកគេ "មានទំនាស់គ្នា"។

ជាសារវន្ត នៅពេលដែល លោក **វ៉ាយដ៍** (Mr. de Wilde) បានសួរទៅកាន់សាក្សី ថាតើលោក **អៀង សារី** មានអំណាចគ្រប់គ្រងយ៉ាងពេញលេញលើក្រសួងការបរទេសឬទេ? សាក្សីបានឆ្លើយថា "បាទ ពួកយើងត្រូវសុំការអនុញ្ញាតពីលោក **អៀង សារី** ។ ក៏ប៉ុន្តែ បើលោក **ប៉ង់** មក គឺលោក **ប៉ង់** នេះអាចសម្រេចមិនអាចប្រាប់លោក **អៀង សារី** ក៏បានដែរ។" លោក **សាឡុត បាន** បាននិយាយថា ពួកគាត់ ត្រូវបានទទួលការណែនាំពីលោក **អៀង សារី** ឲ្យធ្វើអីទៅតាម **ប៉ង់** ចង់បាន។ នៅពេលនោះ ក្រសួងការបរទេសមិនមានសមត្ថកិច្ចរើសបុគ្គលិកផ្សេងៗ ទាំងបញ្ញាជន ឬកសិករ តាមចិត្តនោះទេ។ គឺមានតែ **ប៉ង់** នេះ ដែលជាអ្នករើសបុគ្គលិក ហើយដូចគ្នានេះផងដែរ គាត់ "អាចមានសិទ្ធិយកនរណាទៅក៏បានដែរ"។ សាក្សីរូបនេះ ក៏បាននិយាយផងដែរថា **ប៉ង់** បានរើសយកអ្នកដែលមានប្រវត្តិរូប "ស្អាតស្អំ" ឲ្យចូលធ្វើការក្នុងក្រសួងការបរទេស។ ជាងនេះទៅទៀត គាត់បានបញ្ជាក់ថា ក្រសួងការបរទេស មិនបានមានបន្ទុកនៅក្នុងការទទួលគណៈប្រតិភូ

បរទេសឡើយ ដែលនេះក៏ជាការទទួលខុសត្រូវរបស់ **ប៉ង់** ផងដែរ។ គាត់ បានបដិសេធដោយមិនបានដឹងព័ត៌មានលម្អិតពីរចនាសម្ព័ន្ធទំនាក់ទំនងរវាងក្រសួងការបរទេស និងស្ថានទូតរបស់កម្ពុជាប្រជាធិបតេយ្យនៅឯក្រៅប្រទេសនោះឡើយ។ បន្ថែមពីនេះទៀត លោក **សាឡុត បាន** បានអះអាងនៅពេញមួយសប្តាហ៍នេះថា គាត់មិនបានដឹងថានរណាដែលជាមេរបស់ **ប៉ង់** ឡើយ។

នៅខណៈពេលដែលក្រសួងការបរទេសមិនបានទទួលបន្ទុកលើការរើសបុគ្គលិក និង ទទួលគណៈប្រតិភូបរទេសទេនោះ តាមសាក្សីរូបនេះ បានចងចាំថា ទោះជាយ៉ាងនេះក្តី ក្រសួងនេះបានទទួលបន្ទុកលើ "ទីផ្សាររដ្ឋ"។ "ទីផ្សាររដ្ឋ" គឺជាទីកន្លែងដែលប្រមែប្រមូលផលិតផលមកពីក្រសួង និងការិយាល័យដទៃ ចំណុះអោយក្រសួងការបរទេស ទុកសម្រាប់ផ្គត់ផ្គង់ឲ្យភ្ញៀវ ដែលមកទស្សនកិច្ចក្នុងប្រទេស។ នៅពេលដែលមានដំណើរការពេញលេញ ក្រសួងការបរទេស មានបុគ្គលិកប្រមាណពី១០០ ទៅ៣០០នាក់ ដែលធ្វើការឲ្យទីផ្សាររដ្ឋ។ ចំពោះក្រដាសប្រាក់ធនាគារវិញ មិនត្រូវបានប្រើប្រាស់ឡើយ ដោយសារតែប្រតិបត្តិការទាំងឡាយត្រូវបានធ្វើឡើងតាមរយៈការប្តូរគ្នា។

### *ខ.២. កិច្ចប្រជុំស្វ័យទិតៀន*

យោងតាមលោក **សាឡុត បាន** លោក **អៀង សារី** បានចូលរួមតែកិច្ចប្រជុំធំៗប្រចាំខែតែប៉ុណ្ណោះ។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំទាំងនេះ លោក **អៀង សារី** មិនដែលបាននិយាយលើកឡើងពីមុខតំណែងរបស់សមាជិកក្នុងបក្ស ឬក្នុងគណៈអចិន្ត្រៃយ៍ ឬនិយាយពីការធ្វើសេចក្តីសម្រេចរបស់បក្សឡើយ។ ជំនួសមកវិញ លោក **អៀង សារី** បាននិយាយដដែកពី "សត្រូវ"។ នៅពេលដែលខាងការិយាល័យសហព្រះរាជអាជ្ញា បានសុំឲ្យគាត់ធ្វើការផ្តល់ព័ត៌មានបន្ថែមនោះ សាក្សីបាននិយាយពីអ្នកដែលស្ថិតនៅខាងបិសាច ហើយអ្នកនោះត្រូវធ្វើការកែប្រែ ប្រសិនបើមានធ្វើខុសអ្វីមួយនោះ។ លោក **សាឡុត បាន** បាននិយាយថា សមាជិកត្រូវតែធ្វើការឆ្លុះបញ្ចាំង និងទិតៀនខ្លួនឯង ពីព្រោះ ប្រសិនបើពួកគេមិនបានគ្រប់គ្រងដោយខ្លួនឯងនោះ ពួកគេនឹងមិនអាចរៀបចំប្រទេសជាតិបានឡើយ។ ក៏ប៉ុន្តែ គាត់បានជឿជាក់ថា នៅក្នុងក្រសួងរបស់គាត់ មិនបានមានទណ្ឌកម្មវិន័យឡើយ៖ បើមានសមាជិកធ្វើខុសនោះ គឺមិនមានការចាប់ខ្លួននោះទេ ក៏ប៉ុន្តែពួកគេត្រូវបានផ្លាស់ចេញពីការិយាល័យមួយ ទៅកាន់កន្លែងផ្សេងទៀត ឬបញ្ជូនទៅធ្វើស្រែ ឬចាត់តាំងឲ្យធ្វើការជួសជុលបណ្តាញភ្ជាប់អគ្គិសនី។

ជាការគួរឲ្យកត់សម្គាល់ថា លោក **សាឡុត បាន** បានអះអាងពីការបានឃើញចម្លើយសារភាពពីមន្ទីរ ស-២១ នៅក្នុងក្រសួងការបរទេស។ គាត់បានរម្លឹកថា លោក **អៀង សារី** បានអានចម្លើយសារភាពរបស់ **កុយ ធួន** នៅក្នុងកិច្ចប្រជុំមួយជាមួយនឹងកម្មាភិបាលថ្នាក់មធ្យម និងជាន់ខ្ពស់។ គាត់បានធ្វើការអះអាងថា ពាក្យថា "ប្រជុំ" មិនមែនសំដៅទៅលើការស៊ើបអង្កេតនោះទេ ក៏ប៉ុន្តែវាជាវគ្គអប់រំ ដែលសមមិត្តត្រូវបានទទួលការទូន្មានឲ្យពិចារណាលើបញ្ហាជាច្រើន ហើយមិនឲ្យមានការភ័យខ្លាចថា ថ្នាក់លើណាមួយត្រូវធ្វើការចាប់ខ្លួនឡើយ។ ពួកគេ ត្រូវបានប្រាប់ឲ្យនិយាយតែពាក្យពិត។ ម្ល៉ោះហើយ សាក្សីបានពន្យល់ថា ពុំមានការស៊ើបអង្កេតត្រូវបានធ្វើឡើងនោះទេ។ ការប្រជុំដែលមានទាក់ទងនឹងការរៀនសូត្រស្តីពីសីលធម៌១២ប្រការ ត្រូវបានប្រកាន់ភ្ជាប់ដោយបក្ស។ នៅពេលដែលចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** (Jean-Marc LEVERGNE) បានសួរថាតើលោក **អៀង សារី** បានពន្យល់មូលហេតុអ្វីដែលនាំអោយគាត់អានចម្លើយសារភាពនេះ? លោក

**សាឡុត បាន** បានអះអាងតបថា បន្ទាប់ពីអានចម្លើយសារភាពរបស់ **កុយ ធួន** មក លោក **អៀង សារី** បានសួរទៅកាន់អ្នកដែលចូលរួមប្រជុំថាតើពួកគាត់ធ្លាប់មានទំនាក់ទំនងណាមួយជាមួយនឹង **កុយ ធួន** ឬទេ? ត្រង់ចំណុចនេះ លោក **សាឡុត បាន** បានកាត់យល់ថា លោក **អៀង សារី** បានកំពុងលើកទឹកចិត្តពួកគាត់ឲ្យឆ្លុះបញ្ចាំងពីពួកគាត់។ ក្នុងការឆ្លើយតបទៅនឹងសំណួរថាតើវាមានភាពចាំបាច់ដែរឬទេដែលនាំឲ្យមានការស៊ើបអង្កេតទៅលើបុគ្គលណាដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹង **កុយ ធួន** ហើយថាតើមានចម្លើយសារភាពដែរ ឬទេដែលបានបញ្ជាក់ពីការជាប់ពាក់ព័ន្ធរបស់បុគ្គលិកក្រសួងការបរទេស? លោក **សាឡុត បាន** បានទទួលស្គាល់ថា "ខ្ញុំក៏ព្រួយដែរ មើលទៅគេ ក៏គេទាំងអស់គ្នាបែបព្រួយដូចខ្ញុំដែរហើយមើលទៅ"។ ទោះបីជាយ៉ាងនេះក្តី គាត់បានអះអាងថា មនុស្សជាច្រើនដែលជាប់ពាក់ព័ន្ធក្នុងចម្លើយសារភាព បានបន្តធ្វើការងារនៅក្នុងក្រសួងនេះ ហើយគាត់បានបដិសេធមិនដឹងថាតើពួកគេទាំងនោះ ត្រូវដោះស្រាយការចោទប្រកាន់លើពួកគេ ដែរឬអត់នោះទេ?

## គ. ការចាប់ខ្លួន និងមន្ទីរសន្តិសុខ

ខាងការិយាល័យសហព្រះរាជអាជ្ញា បានសួរសំណួរជាច្រើនទៅកាន់សាក្សីស្តីពី **ប៉ង់** ទំនាក់ទំនងរបស់គាត់ទៅនឹងក្រសួងការបរទេស និងហេតុដែលនាំឲ្យគាត់មានទំនាក់ទំនងនឹងលោក **អៀង សារី** ។

យោងតាមលោក **សាឡុត បាន** ប្រហែលជាមួយទៅពីរខែមុនការមកដល់កងទ័ពវៀតណាម **ប៉ង់** បានមកក្រសួងការបរទេសចំនួនពីរដង ដើម្បី "នាំយក" មនុស្សដែលជាអ្នកបានវិលត្រឡប់មកពីក្រៅប្រទេស។ មានម្តងនោះ **ប៉ង់** បានបញ្ជូនគ្នាឲ្យមកនាំយកមនុស្សពីក្រសួងការបរទេស ដែលបានយកលិខិតណែនាំមកជាមួយ ដោយមានចុះហត្ថលេខារបស់ **ប៉ង់**។[៨] សាក្សីរូបនេះ បានបញ្ជាក់ថា មានមនុស្សប្រហែលជា ២០នាក់ត្រូវបាននាំចេញ ក៏ប៉ុន្តែគាត់មិនបានដឹងថាពួកគេទៅកន្លែងណានោះទេ។ គាត់បានរាយរាប់ថា "នៅពេលដែលមនុស្សត្រូវបានយកចេញពីក្រសួងការបរទេសហើយ គឺមិនដែលត្រលប់មកវិញទេ"។ គាត់បាននិយាយថា គាត់មិនបានដឹងថាតើពួកគេទាំងនោះ ត្រូវបានចាប់ខ្លួន ឬត្រូវគេសម្លាប់ដែរ ឬនោះទេ?

លោក **សាឡុត បាន** បានពន្យល់បន្ថែមថា **ប៉ង់** បានមកក្រសួងនេះនៅពេលណាដែលលោក **អៀង សារី** មិននៅតែប៉ុណ្ណោះ។ គាត់បាននិយាយថា លោក **អៀង សារី** បានដឹងពីការចាប់ខ្លួននេះ តែនៅពេលបន្ទាប់ពី **ប៉ង់** បានធ្វើទៅតាមចិត្តទៅលើពួកគេរួចជាស្រេចទៅហើយ។ ខាងការិយាល័យសហព្រះរាជាអាជ្ញា បានព្យាយាមលើកឡើងពីរបៀបដែលលោក **អៀង សារី** បានដឹងយ៉ាងច្រើនពីអង្គហេតុដែលមនុស្សត្រូវគេយកចេញទៅបាត់។ សហព្រះរាជអាជ្ញា បានអានឲ្យសាក្សីរូបនេះស្តាប់ពីសក្ខីកម្មរបស់គាត់ដែលបានមកពីកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលផ្នែកនោះបានលើកឡើងថា៖

> *ចំពោះអ្នកដែលមកយកមនុស្សនោះ គឺមានឈ្មោះ **ប៉ង់** ។ ពេលដែលបាត់ខ្លួនកម្មាភិបាលបុគ្គលិករបស់ក្រសួង លោក **អៀង សារី** ក៏បានដឹងដែរ។ តែគាត់មិនបាននិយាយអ្វីទេ ខ្លួនគាត់ក៏ភ័យដែរ ហើយខ្ញុំក៏ភ័យដែរ។*

សាក្សីរូបនេះ បានបញ្ជាក់ទទួលស្គាល់សេចក្តីថ្លែងការណ៍ពីមុនរបស់គាត់ ធ្វើឡើងនៅចំពោះមុខខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ក៏ប៉ុន្តែគាត់បានធ្វើការបញ្ជាក់ថា ការដឹងរបស់លោក **អៀង សារី** បាន

ដឹងនៅបន្ទាប់ពេលដែលកម្មាភិបាល និងបុគ្គលិកក្រសួង បានបាត់ខ្លួនរួចទៅហើយ។ នៅពេលដែលមានការសួរបញ្ជាក់ពីលោកប្រធាន **និល ណុន** ចម្លើយតបរបស់សាក្សីរូបនេះ មិនបានស៊ីចង្វាក់គ្នាឡើយត្រង់ថាៈ មានពេលខ្លះ គាត់បាននិយាយថា លោក **អៀង សារី** មិនបានដឹងទេ ហើយមានពេលមួយទៀតនោះ គាត់ស្រាប់តែអះអាងថា លោក **អៀង សារី** បានដឹងបន្ទាប់ពីមនុស្សត្រូវបានគេយកចេញទៅ។ សាក្សីបានបន្តនិយាយថាៈ

> *ដូច្នេះ ខ្ញុំយល់ឃើញថា បើបាត់មនុស្សហើយ គាត់ (លោក **អៀង សារី**) ត្រូវដឹងមូលហេតុហើយ។ គាត់អាចទៅសួរនាំអ្នកដឹកនាំខាងលើៗទៀតហើយ។ ដូច្នេះ គាត់អាចដឹង ក៏ប៉ុន្តែគាត់និយាយមករកខ្ញុំ ដែលខ្ញុំចង់ដឹងដែរហ្នឹង គាត់និយាយមិនបានទេ។*

នៅពេលដែលលោកប្រធាន **និល ណុន** បានសួរទៅកាន់លោក **សាឡុត បាន** ថាតើលោក **អៀង សារី** ក្នុងឋានៈរបស់គាត់ជា ឧបនាយករដ្ឋមន្ត្រីបានដឹងពីការចាប់ខ្លួនមនុស្សដែរ ឬទេ? ហើយតើគាត់មានអារម្មណ៍យ៉ាងម៉េចដែរ? លោក **សាឡុត បាន** បាននិយាយថា "ខ្ញុំមិនដឹងអារម្មណ៍ណាទេ ក៏ប៉ុន្តែខ្ញុំមើលទឹកមុខគាត់ស្រពោន។ ដូចតែគ្នា ខ្ញុំក៏ស្រពោន គេនៅជុំវិញ ក៏ស្រពោន។ ដូច្នេះ សភាពការណ៍ក្នុងមន្ទីរក្នុងពេលនោះ គឺស្រពោនទាំងអស់គ្នាបាទ"។

ជាការគួរឲ្យកត់សម្គាល់នោះ ក្នុងចំណោមបញ្ញាជនដែលបានមកធ្វើការឲ្យក្រសួងការបរទេស មានដូចជា លោក **គាត ឈន់** (បច្ចុប្បន្ន ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងលោក **ចម ប្រាសិទ្ធ** (បច្ចុប្បន្ន ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម)។ លោក **សាឡុត បាន** បានអះអាងថា គាត់បានចងចាំថា ពួកគេទាំងពីរ ត្រូវបានគេ "ឆ្លើយដាក់" ក្នុងអំឡុងពេលនៃរបបនោះ។ ខាងការិយាល័យសហចៅក្រមស៊ើបអង្កេត បានអានកំណត់ហេតុឲ្យសាក្សីរូបនេះស្តាប់ ដោយបញ្ជាក់ថា តាមឲ្យដឹងមក លោក **អៀង សារី** បានប្រាប់លោក **ប៉ុល ពត** ថា ការចាប់ខ្លួនអ្នកទាំងពីរនាក់នេះ នឹងធ្វើឲ្យលុបក្រសួងការបរទេសចោលតែម្តង។

## *គ.១. ប្រជាពលរដ្ឋកម្ពុជា និងមន្ត្រីទូតដែលបានធ្វើមាតុភូមិនិវត្តន៍*

នៅថ្ងៃច័ន្ទ លោក **សាឡុត បាន** បានលើកឡើងថា នៅតាមផ្លូវបំពេញបេសកកម្មទៅសហរដ្ឋអាមេរិកជាមួយនឹងលោក **អៀង សារី** ពួកគាត់បានឈប់សម្រាកនៅទីក្រុង ប៉ារីស ដើម្បីជួបជាមួយប្រជាពលរដ្ឋកម្ពុជាដែលរស់នៅទីនោះ។ នៅពេលដែលគាត់ត្រូវបានសាកសួរជាថ្មីម្តងទៀត កាលពីថ្ងៃពុធ ទាក់ទងនឹងព្រឹត្តិការណ៍នេះ លោក **សាឡុត បាន** បាននិយាយថា "ប្រជាពលរដ្ឋទាំងនោះ មានបំណងវិលត្រឡប់មកស្រុកកំណើតវិញ"។ យោងតាមគាត់បានឲ្យដឹងថា លោក **អៀង សារី** បានប្រាប់ពួកគេថា ពួកគេគួរតែនៅរង់ចាំសិនតែទោះបីជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋទាំងនោះ នៅតែចង់ទៅ ទោះបីជាប្រឈមនឹងការលំបាកយ៉ាងណាក៏ដោយ។ គាត់មិនបានចងចាំពីចំនួនប្រជាពលរដ្ឋកម្ពុជាប៉ុន្មាននាក់ដែលបានវិលត្រឡប់មកវិញឡើយ។

ជាងនេះទៅទៀត សហព្រះរាជអាជ្ញាអន្តរជាតិ លោក **វ៉ាយដ៍** បាននិយាយសំដៅលើសេចក្តីថ្លែងការណ៍មួយដែលលោក **សាឡុត បាន** បានធ្វើទៅឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីឆ្នាំ២០០៧ ដោយទាក់ទងនឹងមន្ត្រីទូតជាច្រើនដែលហៅវិលត្រឡប់មកប្រទេសវិញ ហើយត្រូវបានឃុំខ្លួននៅមន្ទីរ ស-២១ ជាពិសេសមានដូចជា លោក **ហួត សម្បត្តិ** លោក **មាឃ ទូច** ហៅ "**កែម**" លោក **តូច ខាំឿន** និងលោក **អិន លន** ហៅ "**ណាត**" ជាដើម។ នៅក្នុងកំណត់ហេតុនេះ លោក **សាឡុត បាន** បានទទួលស្គាល់ថា គាត់បាន

ស្គាល់ឈ្មោះរបស់អ្នកដែលបានរៀបរាប់ខាងលើនេះ លើកលែងតែឈ្មោះលោក **ហួត សម្បត្តិ** ចេញ។ ក៏ប៉ុន្តែគាត់មិនបានដឹងពីទីកន្លែងដែលពួកគេទាំងនេះត្រូវបានបញ្ជូនទៅនោះទេ។ គាត់បានប្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា៖ "ការសម្រេច គឺគណៈអចិន្ត្រៃយ៍ គឺក្រុមលោក **ប៉ង់** មកពីមន្ទីរមជ្ឈិម ៨៧០ គេជាអ្នកនាំយកទៅ។ លោក **ប៉ង់** ទាក់ទងផ្ទាល់ជាមួយនឹងលោក **អៀង សារី**"។ នៅពេលដែលសុំអោយបញ្ជាក់លើសេចក្ដីថ្លែងការណ៍នេះ លោក **សាឡុត បាន** បាននិយាយថា៖

> *ក្នុងខនេះ ខ្ញុំសូមបដិសេធពាក្យ "ការសម្រេចចិត្តគណៈអចិន្ត្រៃយ៍" លុបចោល បាទ។ ពីមុនមកអាចខ្ញុំភ័ន្តច្រឡំពាក្យពេចន៍អី ហើយខ្ញុំឈឺ ខ្ញុំមិនសូវបានមើលឲ្យត្រឹមត្រូវទេ។ ពេលនេះ ខ្ញុំសូមបដិសេធពាក្យហ្នឹង។ បញ្ហានេះមិនដឹងជាការសម្រេចរបស់ពីណាទេ។ ឃើញក្រុម **ប៉ង់** មក បង **អៀង សារី** គាត់មិនដឹងដែរ អត់ដឹងទេ។ បាទ មិនដឹងជាយ៉ាងណាទេបាទ។*

### *គ.២. បឹងត្របែក*

យោងតាមសាក្សីរូបនេះ គាត់បានដឹងពីបឹងត្របែក នៅពេលដែលគាត់បានរួមដំណើរជាមួយនឹងលោក **អៀង សារី** ទៅកាន់មន្ទីរអប់រំ។ ទស្សនកិច្ចលើកដំបូង ប្រហែលជាកន្លះខែមុនពេលដែលវៀតណាមចូលមក ហើយគាត់ និងលោក **អៀង សារី** បានទៅប្រាប់ឲ្យដឹងមុនថា វៀតណាម បានកំពុងចូលមក។ លោក **សាឡុត បាន** បាននិយាយថា បឹងត្របែក គឺជាទីកន្លែងដែល **ប៉ង់** បានទុកបញ្ញាជន ដែលភាគច្រើនជាអ្នកមកពីក្រៅប្រទេស។ សាក្សីរូបនេះ បានរម្លឹកថា មនុស្សដែលនៅបឹងត្របែក បានស្វាគមន៍គាត់ និងលោក **អៀង សារី** យ៉ាងកក់ក្ដៅ។ គាត់ក៏បាននិយាយផងដែរថា ពួកគេទាំងនោះ ទំនងជារីករាយ ដោយសារតែពួកគេយល់ថា ពួកគេនឹងត្រូវបាន "ដោះលែងឲ្យមានសេរីភាព"។

សាក្សី បានរៀបរាប់ពីមនុស្សដែលឃុំនៅបឹងត្របែកថា ជាបញ្ញាជនល្បីឈ្មោះជាច្រើន ហើយខ្លះទៀត ជាសាស្ត្រាចារ្យដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទៀតផង។ គាត់ បាននិយាយថា ជាពិសេស គាត់បានចងចាំថា លោក **ហោ ណាំហុង** (ដែលបច្ចុប្បន្នជា រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ) បាននៅបឹងត្របែកដែរ ក៏ប៉ុន្តែគាត់មិនបានផ្ដល់ការពន្យល់អ្វីបន្ថែមទៀតឡើយ។ គាត់ បាននិយាយថា គាត់បានចាំពីលោក **យួន ដាវីដ** ច្រើនជាងគេ ពីព្រោះបញ្ញាជនដទៃទៀតដែលត្រូវបានបញ្ជូនមកប្រទេសវិញ បាននិយាយពីលោក **យួន ដាវីដ** ថាជា "សាស្ត្រាចារ្យបង្រៀនសាស្ត្រាចារ្យ" ។ ដោយបានឮដូច្នេះហើយ គាត់បានប្រាប់ទៅលោក **ប៉ុល ពត** ដែលបានស្នើឲ្យគាត់ហ្នឹងធ្វើការត្រួតពិនិត្យតាមដាន ថាតើលោក **យួន ដាវីដ** ពិតជាសក្ដិសមនឹងកិត្តិនាម ជាអ្នកឈ្លាសវៃបំផុតមែន ឬទេ ហើយបានបញ្ជាគាត់ដោយផ្ទាល់ឲ្យលើកទឹកចិត្តដល់លោក **យួន ដាវីដ** ឲ្យធ្វើការឲ្យបក្សកុម្មុយនីស្តកម្ពុជា។ លោក **យួន ដាវីដ** មិនបានធ្វើការឲ្យបក្សកុម្មុយនីស្តកម្ពុជាឡើយ។ លោក **សាឡុត បាន** បាននិយាយថា គាត់មិនបានដឹងថាមានអ្វីកើតឡើងចំពោះសាស្ត្រាចារ្យនោះទេ ក៏ប៉ុន្តែគាត់បានទទួលស្គាល់ថា លោក **យួន ដាវីដ** មិនបាននៅបឹងត្របែកទៀតទេ នៅពេលដែលគាត់បានវិលត្រឡប់មកម្ដងទៀត។ យោងតាមសាក្សីបានឲ្យដឹងថា គាត់បានមានអារម្មណ៍ថា វាមិនត្រឹមត្រូវដែលបញ្ញាជនទាំងអស់នោះ ត្រូវជាប់ឃុំនៅបឹងត្របែក។ លោក **សាឡុត បាន** បាននិយាយថា គាត់បានទៅ

កាន់បឹងត្របែក ចំនួនពីរដងជាមួយនឹងលោក **អៀង សារី** ហើយចំនួនពីរដងទៀតដោយខ្លួនឯង។ នៅពេលចុងក្រោយបង្អស់ គឺគាត់បានទៅកាន់ទីនោះ ដើម្បីធ្វើការជម្លៀសបញ្ញាជនទាំងនោះចេញ។

### *គ.៣. ច្រាំងចំរេះ*

មេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ផេត វណ្ណលី** បានសួរសំណួរដេញដោលទៅកាន់លោក **សាឡុត បាន** ស្តីពីច្រាំងចំរេះ។ សាក្សីរូបនេះ បានផ្តល់សាក្សីថា វាមានទីតាំងស្ថិតនៅភាគខាងជើងនៃទីក្រុងភ្នំពេញ ក្បែរផ្លូវជាតិ។ ថ្វីបើពុំមានភាពច្បាស់លាស់អំពីពេលវេលាដែលវាត្រូវបានបង្កើតក៏ដោយ គាត់បាននិយាយថា វាបានស្ថិតក្នុងតំបន់ភូមិភាគ ៣០៤ ហើយបានក្លាយជាផ្នែកមួយរបស់ក្រសួងការបរទេសនៅក្នុងឆ្នាំ ១៩៧៧។ លោក **អៀង សារី** បានចាត់ឲ្យគាត់មើលការគ្រប់គ្រងច្រាំងចំរេះ នៅចុងឆ្នាំ១៩៧៧ ជាមួយគ្នានឹង **ជាម** ហើយនិង **តាជាង** ដែលជាប្រធានការិយាល័យនេះ។ លោក **សាឡុត បាន** បានមើលការគ្រប់គ្រងមនុស្សចាប់ពី ៧០ទៅ១០០នាក់ ឲ្យធ្វើស្រែ ធ្វើចម្ការ និងនេសាទត្រី។ នៅច្រាំចំរេះ ពុំមានពួកបញ្ញាជនឡើយ។ លោក **សាឡុត បាន** បានពន្យល់ថា មនុស្សទាំងអស់នោះ មិនអាចដើរហើយដោយសេរីតាមចិត្តបាននោះទេ។ មនុស្សគ្រប់គ្នា ត្រូវតែម្ចាស់ការលើខ្លួនឯង ហើយបរិភោគជាសហមូភាព។ គាត់បានរម្លឹកថា បានរៀបចំការប្រជុំទិតៀនខ្លួនឯងយ៉ាងទៀងទាត់ ក៏ប៉ុន្តែមិនមានការកត់សំគាល់លើកំហុសធ្ងន់ធ្ងរណាមួយ ហើយក៏ពុំមាននរណាម្នាក់ត្រូវបានចោទប្រកាន់ថាគិញឡើយ។

គាត់បានធ្វើការអះអាងថា គាត់ និងលោក **អៀង សារី** បាននាំភ្ញៀវបរទេសមកធ្វើទស្សនកិច្ចនៅច្រាំងចំរេះបានច្រើនផងដែរមុនឆ្នាំ១៩៧៧។ តាមឲ្យដឹងមក លោក **អៀង សារី** កម្របានទៅទីកន្លែងនោះណាស់ បន្ទាប់ពីសាក្សីរូបនេះបានមើលការខុសត្រូវនៅទីនោះ ពីព្រោះលោក **អៀង សារី** មានភារៈរវល់ធ្វើដំណើរទៅក្រៅប្រទេស។

## ឃ. ក-១[9] និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា

យោងតាមសាក្សីរូបនេះបានឲ្យដឹងថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានស្នាក់នៅក្នុង **ក-១**។ គាត់បានរម្លឹកថា គាត់បានឃើញមេដឹកនាំទាំងនោះកំពុងប្រជុំគ្នានៅ **ក-១** ក៏ប៉ុន្តែគាត់មិនបានដឹងពីរបៀបវារៈនៃកិច្ចប្រជុំនោះទេ។ គាត់បាននិយាយថា គាត់ជាយុទ្ធជនតូចតាចប៉ុណ្ណោះ ហើយគាត់មិនដែលបានចូលរួមក្នុងកិច្ចប្រជុំណាមួយរបស់គណៈកម្មាធិការមជ្ឈិមបក្សឡើយ។

សាក្សីរូបនេះ បានបញ្ជាក់ថា គាត់ធ្លាប់បានដឹង និងបានទៅកាន់ **ក-១** ពីព្រោះប្រពន្ធរបស់គាត់បានធ្វើការនៅទីនោះជាចុងភៅនៅពេលនោះ។ គាត់បានធ្វើការពន្យល់ថា ផ្ទះបាយស្ថិតនៅខាងក្រៅបរិវេណការិយាល័យ **ក-១** ហើយបើសិនជាគាត់មកជួបប្រពន្ធរបស់គាត់នៅទីនោះ អ្នកយាមក៏មិនបានត្រួតពិនិត្យគាត់ដែរ។ ក៏ប៉ុន្តែ ពួកគេបានឆែកឆេរគាត់នៅពេលណាដែលគាត់ត្រូវទៅការិយាល័យ **ក-១** ដើម្បីនាំយកសំបុត្ររបស់លោក **អៀង សារី** ប៉ុណ្ណោះ។

នៅខណៈពេលដែលសក្ខីកម្មភាគច្រើនក្នុងអំឡុងពេលនៃសប្តាហ៍នេះ បានពាក់ព័ន្ធនឹងលោក **អៀង សារី** ភាគីទាំងអស់ ក៏បានសាកសួរទៅកាន់សាក្សីរូបនេះអំពីតួនាទីរបស់ជនជាប់ចោទដទៃទៀតផងដែរ។ នៅថ្ងៃច័ន្ទ លោក **សាឡុត បាន** បានធ្វើការអះអាងទៅលើសេចក្តីថ្លែងការណ៍ពីមុន ដែលគាត់បានផ្តល់ទៅឲ្យ

ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលគាត់បាននិយាយថា៖ "នេះបានន័យថា **ប៉ុល ពត** មិនអាចធ្វើសេចក្តីសម្រេចតែម្នាក់ឯងទេ បើតាមខ្ញុំដឹងហ្នឹងគឺថា ពូ **ប៉ុល ពត** ជាអ្នកទទួលបន្ទុកខាងនយោបាយ ហើយបង **នួន ជា** ទទួលបន្ទុកខាងកិច្ចការរៀបរយរដ្ឋបាល"។ នៅថ្ងៃព្រហស្បតិ៍ មេធាវីអន្តរជាតិប្រឹក្សាក្តីឲ្យជនជាប់ចោទ **អៀង សារី** គឺលោក **ម៉ៃខល កាណាវ៉ាស** (Mr. Michael Kanavas) បានសួរសំណួរទៅកាន់សាក្សីរូបនេះ ពីភាពសម្អាងលើអ្វីដែលនាំឲ្យគាត់មានការជឿជាក់ថា **ប៉ុល ពត** ទទួលបន្ទុកខាងនយោបាយ ហើយលោក **នួន ជា** ទទួលបន្ទុកលើការចាត់តាំងអង្គការ។ ជាក់ស្តែង លោក **សាឡុត បាន** បានធ្វើការសន្និដ្ឋានដូច្នេះ គឺដោយសារតែ **ប៉ង់** បានប្រាប់គាត់ថា **ប៉ុល ពត** ចង់បានលោក **ហ៊ូ យន់** មកធ្វើជាលេខារបស់គាត់ (**ប៉ុល ពត**)។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារការថ្លែងរបស់ខ្លួននេះមិនបាននាំឲ្យមានការជឿជាក់ជាផ្លែផ្កា លោក **សាឡុត បាន** បានសន្និដ្ឋានថា **ប៉ុល ពត** មិនអាចធ្វើសេចក្តីសម្រេចបានដោយខ្លួនគាត់តែម្នាក់ឡើយ។ លោក **សាឡុត បាន** បានរក្សាជំហររបស់គាត់ដោយនិយាយថា គាត់បានឃើញ **តាម៉ុក** មានមតិប្រឆាំងនឹង **ប៉ុល ពត** ហើយថា សមូហភាព ធំជាងការសម្រេចរបស់បុគ្គល។ បន្ទាប់មក លោក **កាណាវ៉ាស** បានព្យាយាមរម្លេចឲ្យឃើញថា ការយកសម្អាងដែលទាក់ទងនឹងការប្រឆាំងរបស់ **តាម៉ុក** នេះ គឺបានកើតមានឡើងបន្ទាប់ពីអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ដោយសួរទៅកាន់សាក្សីថាតើគាត់ថ្លែងនេះដោយដកស្រង់នូវឧប្បត្តិហេតុដែលបានកើតឡើងរវាង **ប៉ុល ពត** និង **តាម៉ុក** នៅចន្លោះឆ្នាំ១៩៨៦ និង ១៩៨៧ បន្ទាប់ពីលោក **សុន សេន** និងក្រុមគ្រួសាររបស់គាត់ត្រូវបានគេធ្វើឃាត ដែលត្រូវបានគេសន្និដ្ឋានថាជាការបញ្ជារបស់ **ប៉ុល ពត** នោះ។ សាក្សី បានយល់ស្របទៅនឹងការលើកឡើងដោយលោក **កាណាវ៉ាស**។

ទាក់ទងនឹងលោក **ខៀវ សំផន** សាក្សីបាននិយាយថា គាត់មិនបានដឹងពីតួនាទីរបស់ជនជាប់ចោទរូបនេះទេចាប់តាំងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩។ យោងតាមការសួរដេញដោលបន្ថែម សាក្សីបាននិយាយថា លោក **ខៀវ សំផន** បានទទួលបន្ទុក "ប្រមូលកម្លាំង" ហើយគាត់បានសន្មតថា លោក **ខៀវ សំផន** ជាអ្នកទទួលខុសត្រូវលើការិយាល័យ ៨៧០។ នៅពេលដែល លោក **វ៉ាយជ៍** បានសុំឲ្យលោក **សាឡុត បាន** រាយរាប់ពីតួនាទីរបស់លោក **ខៀវ សំផន** នៅក្នុងការិយាល័យ ៨៧០ ដោយប្រៀបធៀបជាមួយនឹងតួនាទីរបស់ **ប៉ង់** សាក្សីបាននិយាយថា ការទទួលខុសត្រូវរបស់មេដឹកនាំទាំងពីរនេះ មិនអាចធ្វើការវែកញែកឲ្យបានច្បាស់ឡើយ។ ក៏ប៉ុន្តែ គាត់ពិតជាបាននិយាយថា លោក **ខៀវ សំផន** តែងតែធ្វើការនៅខាងក្នុងការិយាល័យ រីឯ **ប៉ង់** វិញ ជាធម្មតា នៅក្រៅដោយមានជិះម៉ូតូរបស់ផងដែរ។ សាក្សីរូបនេះ បានចងចាំពីការធ្លាប់បានឃើញលោក **ខៀវ សំផន** នៅក្នុងក្រសួងការបរទេស ក៏ប៉ុន្តែគ្រាន់តែជាការនិយាយពីសំបុត្រយន្តហោះ ឬការប្រមូលយកព័ត៌មានសម្រាប់ធ្វើសុន្ទរកថាតែប៉ុណ្ណោះ។ គាត់បានរំឭកថា **ប៉ង់** បានសុំការណែនាំពី **ប៉ុល ពត** ទាក់ទងនឹងគម្រោងការិយាល័យទាំងឡាយ។

លោក **សាឡុត បាន** ក៏បានពន្យល់ពីការយល់ដឹងរបស់គាត់អំពី "អង្គការ"។ កាលពីពេលព្រឹកថ្ងៃព្រហស្បតិ៍ នៅពេលដែលចៅក្រម **ឡាវែន៍** បានសួរសំណួរ ថាតើលោក **ប៉ុល ពត** ជាមេអង្គការ ឬទេ? លោក **សាឡុត បាន** បានឆ្លើយតបថា លោក **ប៉ុល ពត** គឺជាបុគ្គលមួយរូបនៅក្នុងអង្គការ៖ "ជាម្ជុលមួយនៅក្នុងសមុទ្រ"។ គាត់បាននិយាយថា គាត់មិនបានដឹងថាតើលោក **នួន ជា** ក៏ជាម្ជុលមួយនៅក្នុងសមុទ្រដែរឬយ៉ាងណា? ក៏ប៉ុន្តែគាត់បាននិយាយថា លោក **អៀង សារី** ជាសមាជិកម្នាក់របស់អង្គការ។ ទោះបីជាយ៉ាងនេះក្តី លោក **សាឡុត បាន** បាននិយាយថា ចៅក្រម **ឡាវែន៍** គួរតែសួរជនជាប់ចោទទាំងនោះដោយផ្ទាល់ទៅ ហើយ

បានធ្វើការបញ្ជាក់ដូចតទៅថា៖ "ខ្ញុំគ្រាន់តែពន្យល់ថា អង្គការ គឺជាប្រជាធិបតេយ្យប្រមូលផ្តុំ ប្រមូលផ្តុំបុគ្គល ប្រមូលផ្តុំជារួម បុគ្គលទទួលខុសត្រូវដោយឡែកតែប៉ុណ្ណោះ"។ ក៏ប៉ុន្តែ នៅពេលរសៀលថ្ងៃព្រហស្បតិ៍ លោក **សាឡុត បាន** បានទទួលស្គាល់ថា **ប៉ុល ពត** មិនដែលធ្លាប់បានពន្យល់ពីទំហំនៃអំណាចរបស់គាត់ ពីការធ្វើសេចក្តីសម្រេចដោយគាត់ និងមេដឹកនាំដទៃទៀតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬពីរបៀបដែលពួកគាត់ធ្វើសេចក្តីសម្រេចឡើយ។ សាក្សីរូបនេះ ក៏បាននិយាយផងដែរថា លោក **ប៉ុល ពត** មិនបានពន្យល់ថាតើអង្គការមានអត្ថន័យសំដៅទៅនរណាឬអ្វីឡើយ?

សាក្សីរូបនេះ បាននិយាយថា គាត់មិនដែលបានទទួលឯកសារពីគណៈអចិន្ត្រៃយ៍ ឬបានចូលរួមនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ឡើយ។ លោក **សាឡុត បាន** បាននិយាយថា គ្មាននរណាម្នាក់បានប្រាប់គាត់ជាផ្លូវការពីសមាជិករបស់គណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ឡើយ។ គាត់ក៏បានលើកឡើងផងដែរថា **ប៉ង់** មិនដែលធ្លាប់បានទម្លាយប្រាប់ថាតើ **ប៉ង់** ធ្លាប់បានចូលរួមកិច្ចប្រជុំគណៈមជ្ឈិមដែរ ឬទេ? សាក្សីរូបនេះ បានបង្ហើបប្រាប់ថា គាត់បានធ្វើការសន្និដ្ឋានដោយខ្លួនគាត់អំពីសមាជិកភាពរបស់អង្គភាពសំខាន់ៗនៃបក្សកុម្មុយនីស្តកម្ពុជា ទៅតាមអ្វីដែលគាត់បានមើលឃើញនៅពេលពួកគេនៅក្នុងព្រៃ ដោយតាមរយៈការសង្កេតទៅលើកិច្ចប្រជុំធំៗ ដែលបានរៀបចំឡើង ហើយតាមរយៈអ្វីដែលគាត់បានឮពីមនុស្សមួយចំនួន។ សាក្សីបាននិយាយបញ្ជាក់ថា មានពាក្យចចាមអារ៉ាមថា **ប៉ង់** អាចបានក្លាយជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ក៏ប៉ុន្តែគាត់មិនបានដឹងថាតើវាគឺជាការពិតដែរ ឬអត់?

## ង. ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា

សាក្សី **សាឡុត បាន** បានទទួលស្គាល់ថា គាត់មិនបានដឹងច្បាស់អំពីទស្សនៈរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងមេដឹកនាំរបស់បក្សឡើយ ទោះបីជាគាត់ធ្លាប់បានរស់នៅជាមួយនឹងឪពុកមារបស់គាត់ គឺលោក **ប៉ុល ពត** ក៏ដោយ។ ទោះបីជាយ៉ាងនេះក្តី គាត់បានពិពណ៌នាអំពីទស្សនៈឪពុកមារបស់គាត់ថាជាទស្សនៈ "ព្រហ្មមិ ពុទ្ធិ អមិរៈកសៈ"។ គាត់ក៏បានជជែកត្រង់ចំណុចនេះថា បក្សកុម្មុយនីស្តកម្ពុជា បានឲ្យតម្លៃទៅលើអ្នកណាដែលបានប្រកាន់ភ្ជាប់សីលធម៌ទាំង ១២ប្រការ ដែលជាមនុស្ស "ស្អាតស្អំ"។ ចំណែកឯ "វណ្ណៈខ្មាំង" បានសំដៅទៅលើបុគ្គលណាដែលបំផ្លាញជាតិឯង និងកេរអាករជាតិឯង។ លោក **សាឡុត បាន** បានធ្វើការពន្យល់យ៉ាងក្បោះក្បាយអំពី "ខ្មាំង" ក្នុងចរិតលក្ខណៈដូចខាងក្រោម៖

> *ខ្មាំងដែលធំបំផុត គឺខ្មាំងបំផ្លាញពិភពលោក ខ្មាំងដែលបំផ្លាញពិភពលោក គឺខ្មាំងដែលបំផ្លាញបរិស្ថាន ទឹក ដី ខ្យល់ ភ្លើង។ សូមលោកជ្រាប។ ព្រឹកមិញ ខ្ញុំបានជម្រាបហើយ ភ្លេចឲ្យសូន្យ យើងទាំងអស់គ្នាភ្លេចឲ្យសូន្យ។ បានត្រឹមតែ (សំណុំរឿង) ០១ បានត្រឹមតែ (សំណុំរឿង) ០២ តែប៉ុណ្ណោះ។ សូមអភ័យទោស សូមជ្រាប។*[10]

ទាក់ទងនឹងបុព្វជិតព្រះពុទ្ធសាសនា លោក **សាឡុត បាន** បាននិយាយថា ពួកគេមិនត្រូវបានចាត់ទុកថាជាខ្មាំងឡើយ ហើយក៏មិនត្រូវបានបង្ខំឲ្យផ្សឹកផងដែរ។ សាក្សីរូបនេះ បានអត្ថាធិប្បាយថា មជ្ឈដ្ឋានកប៉ាល់ហោះស៊ើបការណ៍របស់សហរដ្ឋអាមេរិក បានបាញ់រះសំដៅទៅលើមនុស្សដែលមានពាក់ស្បង់ពណ៌ទឹកក្រូច

ដែលជាព្រះសង្ឃ ហើយប្រការនេះ ព្រះសង្ឃក៏មកសឹកដោយខ្លួនលោក។ គាត់បានសន្និដ្ឋានថា " ...ដូច្នេះហើយ ព្រះសង្ឃ បានមករួមតស៊ូ"។

### ច. ពាណិជ្ជកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

លោក **សាឡុត បាន** បាននិយាយថា នៅចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧៣ ពាណិជ្ជកម្ម បានមានដំណើរការជា "ធម្មតា" ហើយរបបកម្ពុជាប្រជាធិបតេយ្យ បានប្រើប្រាស់រូបិយវត្ថុជំនាន់រដ្ឋកាល **លន់ នល់** ។ ក៏ប៉ុន្តែ ចាប់ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ ការប្រើប្រាស់រូបិយវត្ថុបានធ្លាក់ចុះ រហូតដល់ឈប់ចាយតែម្តង។ កម្មសិទ្ធិឯកជន ក៏ត្រូវបានលុបបំបាត់ចោលដូចគ្នាផងដែរ តែមិនមែនជាបំណងនោះទេ គឺធ្វើដើម្បីយកឈ្នះលើសត្រូវ។ សាក្សីរូបនេះ បានពន្យល់ថា បក្សកុម្មុយនីស្តកម្ពុជា ត្រូវចាំបាច់បដិសេធចោលនូវបុគ្គលនិយមគឺដោយសារតែ "សភាពការណ៍ជំរុញឲ្យធ្វើដូច្នេះ"។ សមាជិកទាំងអស់ ត្រូវតែធ្វើពលិកម្មដោយ "យកសាច់ញើសឈាម" របស់ពួកគេក្នុងការឧបត្ថម្ភខ្លួនឯង។ លោក **សាឡុត បាន** បានបញ្ជាក់ថា "របបសមូហភាព គឺជាប្រជាធិបតេយ្យប្រមូលផ្តុំ" ក៏ប៉ុន្តែគាត់មិនអាចរម្លឹកពីពេលដែលគោលការណ៍នេះត្រូវបានបង្កើតឡើងនោះទេ។

សាក្សីរូបនេះ បានបន្តធ្វើការបដិសេធលើការយល់ដឹងអំពីសហករណ៍ ហើយបានពន្យល់ថា ការអត់ឃ្លាន ជាទូទៅ បានកើតឡើងក្នុងសម័យសង្គ្រាម។ គាត់បានគូសបញ្ជាក់ថា ការអត់ឃ្លាន គឺបណ្តាលមកពីការមិនអនុវត្តតាមគោលនយោបាយរបស់បក្សនៅក្នុងតំបន់ជាក់លាក់មួយចំនួន។ គាត់ ក៏បានលើកឡើងផងដែរថា មានគោលនយោបាយក្នុងការផ្តល់អាហារឲ្យប្រជាជនបរិភោគគ្រប់គ្រាន់ ហើយថា មុននឹងនរណាម្នាក់ត្រូវបានចោទប្រកាន់ថាបានល្មើសនឹងគោលនយោបាយនេះ បញ្ហានេះត្រូវតែឆ្លងកាត់ឋានានុក្រមប្រាំពីរថ្នាក់សិនមុននឹងសេចក្តីសម្រេចត្រូវបានធ្វើឡើង។ ជាងនេះទៅទៀត លោក **សាឡុត បាន** បានអះអាងថា គាត់មិនបានដឹងពីការធ្វើទារុណកម្មចំពោះការដែលមិនគោរពតាមគោលនយោបាយរបបអាហារឡើយ ដែលនេះបានធ្វើឲ្យលោក **វ៉ាយជំ** ដកស្រង់ចេញពីសេចក្តីថ្លែងការណ៍ពីមុនរបស់គាត់ដែលបានធ្វើនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយនិយាយថា កម្មាភិបាលណាដែលត្រូវបានគេចាប់បានដោយសារតែឲ្យប្រជាជនហូបបាយបបរ កម្មាភិបាលនោះត្រូវគេសម្លាប់។ លោក **សាឡុត បាន** បាននិយាយថា គោលនយោបាយនេះជាគោលនយោបាយថ្មីមួយ ហើយបានបន្តថា វាមិនត្រូវបានយកមកអនុវត្តទេដោយសារតែការមកដល់របស់វៀតណាម។ គាត់បានបញ្ជាក់ថា គាត់មិនបានដឹងពីគោលនយោបាយពីមុនមកដែរ។

## ផ្នែកទី ៣ ៖ បញ្ហាផ្លូវច្បាប់ និងនីតិវិធី

សក្ខីកម្មរបស់លោក **សាឡុត បាន** បានធ្វើឡើងប្រកបដោយបញ្ហារសើបជាច្រើន ដែលទាក់ទងទៅនឹងការធ្វើអត្តសញ្ញាណកម្មទៅលើភស្តុតាង និងសិទ្ធិរបស់សាក្សី។ ជាងនេះទៅទៀត ភាគីទាំងអស់ បានលើកឡើងនូវការជំទាស់ជាច្រើនទៅនឹងសំណួរពេញមួយសប្តាហ៍នេះ ដោយរួមបញ្ចូលទាំងបញ្ហាដែលធ្លាប់កើតមានរួចមកហើយទាក់ទងនឹងសំណួរដឹកមុខ ក៏ដូចជាការតាំងសំណួរដេញដោលដោយមិនមានសម្អាង ឬបញ្ជាក់ច្បាស់លាស់ពីអំឡុងពេលវេលាដែលជាកម្មវត្ថុនៃការចោទសួរនោះ។

## ក.	អត្តសញ្ញាណកម្មលើភស្តុតាង

បញ្ហាចោទ ដែលទាក់ទងនឹងនីតិវិធីនៃការដាក់ឯកសារនៅចំពោះមុខសាក្សី ក៏បានកើតមានឡើងដដែលៗជាច្រើនដង ទោះបីជាអង្គជំនុំជម្រះធ្លាប់បានសម្រេចរួចមកហើយថា នៅពេលដែលសាក្សីបានលើកឡើងថាគាត់មិនដែលធ្លាប់បានឃើញឯកសារដែលលើកបង្ហាញនេះមុនពេលមកផ្តល់សក្ខីកម្ម នោះឯកសារនេះត្រូវតែដកចេញពីមុខសាក្សី ហើយភាគីទាំងអស់ មិនអាចប្រើប្រាស់នូវការសម្អាងលើឯកសារនេះនៅក្នុងការតាំងសំណួររបស់ពួកគេទៀតឡើយ។ នៅក្នុងករណីណាក៏ដោយ ភាគីក៏អាចនៅតែសួរសំណួរសាក្សីទាក់ទងនឹងប្រធានបទដែលជាកម្មវត្ថុនៃឯកសារនេះបានផងដែរ។[11] ម្យ៉ាងវិញទៀត សាក្សី អាចនឹងត្រូវបានសាកសួរដេញដោលអំពីឯកសារមួយ ហើយនិងខ្លឹមសាររបស់វា ប្រសិនបើគាត់ធ្លាប់បានឃើញឯកសារនោះពីមុនមក ទោះក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ឬក្នុងអំឡុងពេលនៃការស៊ើបសួររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។

ករណីមួយដែលបានកើតឡើងយ៉ាងឆាប់រហ័សជ្រុល សម្រាប់កិច្ចពិភាក្សាដេញដោលលើចំណោទបញ្ហា នាសប្តាហ៍នេះ ទាក់ទងនឹងការប្រើប្រាស់ឯកសារដ៏វែងអន្លាយរបស់លោក **វ៉ាយដ៍** ដែលលោក **សាឡុត បាន** បាននិយាយថា គាត់មិនដែលធ្លាប់បានឃើញវាពីមុនមកឡើយ។ បន្ទាប់មក ខាងការិយាល័យសហព្រះរាជអាជ្ញា បានសម្អាងលើកំណត់ហេតុរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានបង្ហាញថា តាមពិត ឯកសារនេះធ្លាប់បានបង្ហាញសាក្សីរួចមកហើយ។ លោក **កាណាវាស** បានធ្វើការជំទាស់ និងបានតវ៉ាឲ្យលោក **វ៉ាយដ៍** ដកឯកសារនេះចេញ ដោយគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះបដិសេធចំពោះការជំទាស់នេះ ដោយបានបញ្ជាក់ថា ស្ថានភាពនេះ មានលក្ខណៈខុសគ្នា ដោយសារតែមានហេតុផលគ្រប់គ្រាន់ក្នុងការជឿជាក់ថា សាក្សីរូបនេះ ធ្លាប់បានឃើញឯកសារនេះក្នុងអំឡុងពេលនៃការស៊ើបសួររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតពិតមែន។ លោកប្រធានអង្គជំនុំជម្រះ សរុបថា បញ្ហាដែលកំពុងចោទឡើងនេះ គឺថាតើសាក្សីរូបនេះធ្លាប់បានឃើញឯកសារទាំងមូល ឬគ្រាន់តែផ្នែកមួយចំនួនដែលមាននៅក្នុងឯកសារនេះ។ អង្គជំនុំជម្រះ បានធ្វើការណែនាំទៅសាក្សីឲ្យមកកាន់បន្ទប់សវនាការឲ្យបានលឿននៅថ្ងៃបន្ទាប់ ដើម្បីធ្វើការពិនិត្យមើលលើឯកសារដែលខាងការិយាល័យសហព្រះរាជអាជ្ញាចង់លើកមកបង្ហាញនោះ។ ថ្វីបើគាត់បានចំណាយពេលវេលាមកពិនិត្យមើលឯកសារទាំងនេះតាមការបង្គាប់របស់អង្គជំនុំជម្រះក៏ដោយ ក៏លោក **សាឡុត បាន** បានធ្វើការបញ្ជាក់យ៉ាងម៉ឺងម៉ាត់ថា គាត់មិនដែលធ្លាប់ឃើញឯកសារទាំងនេះពីមុនមកឡើយ។ គាត់បានពន្យល់បន្ថែមថា ខាងការិយាល័យសហចៅក្រមស៊ើបអង្កេត គ្រាន់តែបានលើកបង្ហាញគាត់តែមួយ ឬពីរទំព័រប៉ុណ្ណោះ ដែលវាមានទម្រង់ខុសគ្នាពីឯកសារដែលដាក់នៅចំពោះមុខគាត់ ហើយថា គាត់មិនបានផ្តិតស្នាមមេរបស់គាត់លើឯកសារទាំងនោះឡើយ។

ភាគីបានបង្ហាញពីមតិយោបល់ខុសៗគ្នារបស់ពួកគាត់ នៅក្នុងការប្រឈមមុខនឹងភាពអល់អែកនេះ។ លោក **កាណាវាស** បានទទួលស្គាល់ថា កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់សាក្សី បានបញ្ជាក់យ៉ាងច្បាស់ថា ខាងការិយាល័យសហចៅក្រមស៊ើបអង្កេត បានបង្ហាញសាក្សីនូវឯកសារ។ ក៏ប៉ុន្តែ លោក **កាណាវាស** បានតវ៉ាថា វានៅតែមិនទាន់ច្បាស់ពីផ្នែកណាមួយឲ្យប្រាកដដែលសាក្សីបានឃើញនោះ។ លោក **កាណាវាស** បានបញ្ចេញយោបល់បន្ថែមថា ប្រការនេះ បានបង្ហាញពីការស៊ើបអង្កេតដែលបានធ្វើឡើងមិនបានល្អ។ លោកស្រី **អេលីហ្សាបេត ស៊ីម៉ុនណូហ្វត** (Ms. Elizabeth Simonneau-Fort) មេធាវីអន្តរជាតិនាំមុខដើម

បណ្តឹងរដ្ឋប្បវេណី បានបញ្ចេញមតិយោបល់ថា មានភស្តុតាងយ៉ាងសំខាន់ដែលបញ្ជាក់ថា សាក្សីពិតជាធ្លាប់បានឃើញឯកសារទាំងនេះមែន។ លោកស្រីបាននិយាយថា ពួកគេមិនអាចបំបែកភស្តុតាងឯកសារចេញពីភស្តុតាងដែលបានមកពីការផ្តល់សក្ខីកម្មបានឡើយ ហើយបានសម្តែងការងឿងឆ្ងល់ពីហេតុអ្វីបានជាមិនអាចជជែកពិភាក្សាគ្នាលើឯកសារនេះនៅចំពោះមុខសាក្សីនេះបាន ដោយសារគ្រាន់តែមូលហេតុដែលសាក្សីនេះបានអះអាងថា មិនដែលធ្លាប់បានឃើញឯកសារនេះពីមុនមក? លោកស្រី **ស៊ីម៉ុនណូហ្សូត** បានបន្ថែមថា សាក្សី អាចមើលឯកសារ ហើយភាគីគួរតែអាចសួរសាក្សីអំពីអ្វីដែលគាត់ដឹងពីឯកសារនោះ "ក៏ប៉ុន្តែយើងសម្រេចថា ឯកសារមិនអាចជជែកដេញដោល ហើយបង្ហាញជូនសាក្សីដោយសារតែសាក្សីនិយាយថា គាត់មិនដែលធ្លាប់ឃើញនេះគឺជាការកាត់ផ្តាច់ គឺជាការដកហូតនូវមធ្យោបាយភស្តុតាង ហើយខ្ញុំគិតថាទង្វើបែបនេះជាការគួរឲ្យសោកស្តាយណាស់"។ ម្យ៉ាងវិញទៀត លោក **សុន អរុណ** មេធាវីជាតិប្រឹក្សាក្តីឲ្យជនជាប់ចោទ **នួន ជា** បានតវ៉ាទៅអង្គជំនុំជម្រះឲ្យដកឯកសារនេះចេញ ដោយសារតែសាក្សីរូបនេះបានបញ្ជាក់យ៉ាងច្បាស់ហើយថា គាត់មិនបានចាំឯកសារនេះឡើយ។ គាត់បានតវ៉ាថា ខាងសហព្រះរាជអាជ្ញា និងខាងមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី មិនគួរបង្ខំសាក្សីឲ្យឆ្លើយនោះឡើយ។

លោកប្រធានអង្គជំនុំជម្រះ **និល ណុន** បានគូសបញ្ជាក់ថា កំណត់ហេតុរបស់ខាងការិយាល័យសហចៅក្រមស៊ើបអង្កេត សំដៅដល់ឯកសារដែលខាងការិយាល័យសហព្រះរាជអាជ្ញាបានកំពុងលើកបង្ហាញ។ ដូច្នេះ វាសមគួរដែលថាឯកសារទាំងនេះត្រូវបានបង្ហាញរួចហើយក្នុងអំឡុងពេលនៃការស៊ើបសួរ។ លោកប្រធាន បានណែនាំទៅកាន់លោក **វ៉ាយដ៏** ឲ្យធ្វើកំណត់សម្គាល់ឲ្យបានច្បាស់លាស់លើទំព័រណាមួយដែលត្រូវបានបង្ហាញទៅឲ្យសាក្សី ក្នុងករណីដែលឯកសារ "ដុំ" ទាំងមូល មិនបានបង្ហាញជូនគាត់។ លោក **វ៉ាយដ៏** សុខចិត្តទទួលយក ហើយបានធ្វើការកត់សម្គាល់លើកំណត់ហេតុរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចំនួនសំណួរ លេខយោងឯកសារភស្តុតាងជាបីភាសា និងកម្មវត្ថុនៃសំណួរដេញដោល។ តែទោះបីជាយ៉ាងណាក៏ដោយ សាក្សីរូបនេះ បានបដិសេធចំពោះការធ្លាប់ឃើញឯកសារនេះក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេត។ ដោយក្តៅក្រហាយពេក លោក **វ៉ាយដ៏** បានបញ្ជាក់ថា គាត់ "មិនទៅមុខសោះ" ហើយបានកំពុង "បាត់បង់ពេលវេលា" មុននឹងប្រគល់ជូនបញ្ហានេះឲ្យអង្គជំនុំជម្រះជាអ្នកសម្រេច។

អង្គជំនុំជម្រះសាលាដំបូង បានគ្រប់គ្រងការតាំងសំណួរវិញម្តង ក៏ប៉ុន្តែសាក្សីនៅតែចចេសដោយបញ្ជាក់ថា គាត់មិនបានធ្លាប់ឃើញឯកសារទាំងនេះឡើយ។ នៅពេលក្រោយមក រឿងហេតុបានលេចឡើងច្បាស់ថា សាក្សីរូបនេះ បានគិតថាអង្គជំនុំជម្រះបានកំពុងសួរថាតើគាត់មានបានសរសេរកំណត់សម្គាល់លើឯកសារដែលបានប្រកែកគ្នា ហើយបើដូច្នេះមែន គាត់ត្រូវទទួលខុសត្រូវលើឯកសារដែលមានចំណាររបស់គាត់។ លោកប្រធាន **និល ណុល** បានធានាអះអាងចំពោះលោក **សាឡុត បាន** ថា អង្គជំនុំជម្រះមិនបានកំពុងព្យាយាមបង្ខំឲ្យគាត់ទទួលស្គាល់ថា គាត់បានសរសេរកំណត់សម្គាល់លើឯកសារទាំងនេះទេ ក៏ប៉ុន្តែបានកំពុងធ្វើការស្នើសុំការបញ្ជាក់ថា តើគាត់ធ្លាប់បានឃើញឯកសារទាំងនេះដែរឬទេ នៅក្នុងអំឡុងពេលធ្វើបទសម្ភាសន៍របស់គាត់ជាមួយនឹងខាងការិយាល័យសហចៅក្រមស៊ើបអង្កេត? បន្ទាប់ពីបានចំណាយពេលអស់ជិតមួយម៉ោងក្នុងការបញ្ជាក់លើបញ្ហានេះមក អង្គជំនុំជម្រះបានសម្រេចថា សាក្សីមិនបានចងចាំឯកសារទាំងនេះឡើយ ហើយបានណែនាំទៅខាងសហព្រះរាជអាជ្ញាឲ្យបន្តការតាំងសំណួររបស់ពួកគេទៅកាន់សាក្សីរូបនេះដោយសួរសំណួរទូទៅវិញ។

## ខ.	ការគាំពារសាក្សី៖ សិទ្ធិប្រឆាំងនឹងការធ្វើពិរុទ្ធភាពខ្លួនឯង និងតួនាទីមេធាវីប្រឹក្សា

ចាប់តាំងពីការចាប់ផ្ដើមនៃការធ្វើសក្ខីកម្មរបស់គាត់នៅថ្ងៃច័ន្ទមក លោក **សាឡុត បាន** បានមានជំនួយការដែលជា "មេធាវីប្រឹក្សា" (មេធាវីដែលត្រូវបានតែងតាំងដោយអង្គជំនុំជម្រះក្នុងការធានាថា សិទ្ធិរបស់គាត់ដែលជាសាក្សីត្រូវបានការពារ)។ បន្ទាប់ពីបានរម្លឹកលោក **សាឡុត បាន** ពីសិទ្ធិរបស់គាត់ប្រឆាំងនឹងការធ្វើពិរុទ្ធភាពខ្លួនឯងរួចមក លោកប្រធាន **និល ណុន** បានរម្លឹកដល់មេធាវីប្រឹក្សាឲ្យផ្ដល់យោបល់លោក **សាឡុត បាន** មិនឲ្យឆ្លើយទៅនឹងសំណួរទាំងឡាយណា ប្រសិនបើចម្លើយរបស់គាត់អាចនឹងដាក់ពិរុទ្ធភាពមកលើខ្លួនគាត់នោះ។[12]

កាលពីថ្ងៃច័ន្ទពេលរសៀល មេធាវីប្រឹក្សាឲ្យលោក **សាឡុត បាន** បានអន្តរាគមន៍ បន្ទាប់ពីខាងសហព្រះរាជអាជ្ញាសួរដេញដោលទៅកាន់សាក្សីពីនរណាដែលជាអ្នកទទួលបន្ទុកលើក្រសួងការបរទេស នៅពេលណាដែលលោក **អៀង សារី** ជាប់បំពេញបេសកកម្ម។ មេធាវីប្រឹក្សា បាននិយាយថា ដោយសារតែសំណួរនេះធ្លាប់បានសួរមកហើយ ការលើកឡើងសំណួរដដែលនេះម្ដងទៀត អាចជាបច្ច័យនាំឲ្យសាក្សីឆ្លើយនូវចម្លើយដែលដាក់ពិរុទ្ធភាពលើខ្លួនឯងជាមិនខាន។ ជាការឆ្លើយតបវិញ លោកប្រធាន **និល ណុន** បានណែនាំឲ្យមេធាវីប្រឹក្សាសួរបញ្ជាក់ទៅកាន់លោក **សាឡុត បាន** ថាតើគាត់ចង់ធ្វើការឆ្លើយនឹងសំណួរនេះដែរ ឬអត់? លោកប្រធាន បានសង្កត់ធ្ងន់ថា តួនាទីរបស់មេធាវីប្រឹក្សា គឺពិភាក្សាលើការឆ្លើយដាក់សំណួរជាមួយនឹងសាក្សី តែការសម្រេចផ្ដល់ចម្លើយ ឬរក្សាភាពស្ងៀមស្ងាត់ត្រូវស្ថិតនៅលើសាក្សីខ្លួនឯង។ បន្ទាប់ពីបានប្រឹក្សាយ៉ាងខ្លីមួយរវាងលោក **សាឡុត បាន** ជាមួយនឹងមេធាវីប្រឹក្សារបស់គាត់ សាក្សីរូបនេះបានស្នើសុំឲ្យលោក **វ៉ាយជ៌** ធ្វើការអានសំណួរនេះឡើងវិញម្ដងទៀត។ លោក **សាឡុត បាន** បានឆ្លើយតបថា គាត់មិនអាចចងចាំថានរណាជាដឹកនាំកិច្ចប្រជុំនៅក្នុងក្រសួងការបរទេសនៅពេលដែលលោក **អៀង សារី** បានអវត្តមាននោះឡើយ។

លោក **សាឡុត បាន** បាននៅអមដោយមេធាវីប្រឹក្សាថ្មីម្នាក់ទៀតនៅថ្ងៃអង្គារ។ លោកប្រធាន **និល ណុល** បានកត់សម្គាល់ពីការផ្លាស់ប្ដូរមេធាវីប្រឹក្សា ហើយបានសួរនាំថាតើសាក្សីមានបញ្ហាអ្វីដែរ ឬទេ? លោក **សាឡុត បាន** បានឆ្លើយថាមិនមានបញ្ហាអ្វីទេ។ នៅពេលដែលមានសំណួរសួរពីចំនួនដងនៃពេលវេលាដែលគាត់បានមកមើលប្រពន្ធរបស់គាត់នៅក-១ លោក **សាឡុត បាន** បានបដិសេធមិនឆ្លើយ ដោយបានលើកឡើងពីសុបិនមួយដែលគាត់បានយល់សប្តិថា "លោកតាដំបងដែក (ជាទេពតាមួយអង្គនៅក្នុងទេវកថារបស់ប្រជាជនកម្ពុជា)[13] បានប្រមូលបុព្វការីជនទាំងអស់មកប្រាប់ខ្ញុំថា "ឯង! កុំនិយាយអីផ្ដេសផ្ដាស។ ឯង! ត្រូវគិតភាសាខ្មែរឲ្យច្បាស់ សិរីសួស្ដី។ ពាក្យ "សិរីសួស្ដី" បើសំណួរណាមិនមានសិរីសួស្ដីទេ ឯង! មិនត្រូវស្ដីរកទេ"។ តាមឲ្យដឹងមក លោកតាដំបងដែក បានប្រាប់គាត់ថា តុលាការនេះ គឺ "អត់យុត្តិធម៌" នោះទេ គឺ អត់ "យុត្តិធម៌ ១០០ភាគរយ"។ ជាបច្ច័យមក លោក **សាឡុត បាន** បានជឿជាក់ថា សំណួរដេញដោលកាលពីថ្ងៃច័ន្ទ បានឆ្លើយដាក់គាត់រួចទៅហើយ។ គាត់បានបង្ហាញពីភាពភ័យខ្លាចដែលអាចនឹងចោទប្រកាន់មកលើរូបគាត់នៅថ្ងៃអនាគត។

លោកប្រធានអង្គជំនុំជម្រះ បានធ្វើការធានាអះអាងចំពោះលោក **សាឡុត បាន** ថា ពុំមានសំណួរណាមួយដែលបានស្នើឲ្យដាក់ពិរុទ្ធភាពមកលើខ្លួនគាត់ឡើយ។ លោកប្រធាន **និល ណុន** ក៏បានរម្លឹកដល់សាក្សីរូបនេះពីកាតព្វកិច្ចរបស់គាត់ក្នុងការសហការជាមួយនឹងអង្គជំនុំជម្រះស្វែងរកការពិត ដោយបានធ្វើការ

ពិចារណាថ្លឹងថ្លែងទៅលើការការពារសិទ្ធិរបស់គាត់ប្រឆាំងនឹងការដាក់ពិរុទ្ធភាពមកលើខ្លួនគាត់។ ជាងនេះទៅទៀត លោកប្រធានអង្គជំនុំជម្រះ បានណែនាំទៅកាន់លោក **សាឡុត បាន** ថា គាត់មានសេរីភាពក្នុងការប្រឹក្សាជាមួយនឹងមេធាវីប្រឹក្សារបស់គាត់មុននឹងគាត់ឆ្លើយសំណួរដេញដោល។ ក៏ប៉ុន្តែ អង្គជំនុំជម្រះ មិនអាចធ្វើការពិចារណាទៅលើអបិយជំនឿ និងសុបិន ក្នុងការជំនុំជម្រះបានឡើយ។ លោកប្រធាន **និល ណុន** ក៏បានក្រើនរម្លឹកដល់មេធាវីប្រឹក្សាឲ្យធ្វើការវិភាគសំណួរដែលបានសួរទៅកាន់សាក្សី។ នៅទីបញ្ចប់ សាក្សីបាននិយាយថា "បាទ ខ្ញុំសូមឯកភាពតាមលោកប្រធានតុលាការ។ ដូច្នេះ ខ្ញុំគ្រាន់តែសំណូមពរថា សូមតុលាការមានអីខុសឆ្គង ក៏សូមថា កុំឲ្យខ្ញុំប្រើពាក្យថា "វ័ណ្ឋក" មកខ្ញុំផង" ។

## គ. ការយោងទៅលើសេចក្តីថ្លែងការណ៍របស់សាក្សីដទៃ

នៅថ្ងៃព្រហស្បតិ៍ លោកចៅក្រម **ឡាវែន៍** បានប្រើប្រាស់សេចក្តីថ្លែងការណ៍របស់ **ឌុច** មកសួរដេញដោលទៅកាន់លោក **សាឡុត បាន** ថាតើគាត់ធ្លាប់បានឃើញសមាជិកនៃរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK) ឬរណសិរ្សរួបរួមជាតិកម្ពុជា (FUNK) នៅច្រាំងចំរេះដែរ ឬទេ? ចៅក្រមរូបនេះ ក៏បានប្រើប្រាស់ផងដែរនូវសក្ខីកម្មរបស់សាក្សីដទៃទៀតដែលមានអត្តលេខ (TCW 729) ដើម្បីសួរដេញដោលទៅកាន់លោក **សាឡុត បាន** ស្តីពីការចាប់ខ្លួនទៅលើសម្ព័ន្ធមិត្តរបស់ **កុយ ធួន** ដែលគេសន្មតថា ត្រូវបានបញ្ជូនទៅកាន់ច្រាំងចំរេះ។ ជាលទ្ធផល លោក **កាណាវ៉ាស** បានចង្អុលបង្ហាញការសម្រេចរបស់អង្គជំនុំជម្រះដែលថា "ការដែលផ្អែកលើឯកសារអ្នកដទៃនោះ គឺគប្បីគួតែរសាក្សីរូបណាដែលឆ្លើយពាក់ព័ន្ធ ព្រោះយើងយកចម្លើយពីមុនយកមកសួរដេញដោលសម្រាប់សាក្សី។"[14] គាត់បានចោទសួរថាតើការសម្រេចនេះ អនុវត្តបានតែទៅលើភាគីហើយមិនអនុវត្តលើអង្គជំនុំជម្រះ? ហើយបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរតែធ្វើការកែសម្រួលឡើងវិញលើការសម្រេចរបស់ខ្លួន។ លោកស្រី **ស៊ីម៉ុនណូហ្សត** បានគាំទ្រនូវការលើកឡើងរបស់លោក **កាណាវ៉ាស** ហើយបាននិយាយថា ពួកគាត់នឹងស្វាគមន៍ចំពោះការកែតម្រូវឡើងវិញលើសេចក្តីសម្រេចនេះ ដោយសារតែភាពសារៈសំខាន់នៃការផ្ទៀងផ្ទាត់ឲ្យគ្នាទៅវិញទៅមកលើសេចក្តីថ្លែងការណ៍ទាំងឡាយ និងឯកសារដែលបានមកពីសាក្សីដទៃ។ មេធាវីអន្តរជាតិការពារក្តីឲ្យលោក **នួន ជា** គឺលោក **មៃខ៊ល ផេស្តមិន** (Mr. Michiel Pestman) ក៏បានធ្វើការបញ្ជាក់អំពីគំនិតស្រដៀងគ្នាផងដែរ។ បន្ទាប់មកពីសម្រាកភ្លាមៗ លោកចៅក្រម **ឡាវែន៍** បានបញ្ជាក់ថា អង្គជំនុំជម្រះមិនបានកំពុងធ្វើការកែសម្រួលលើសេចក្តីសម្រេចមុនៗរបស់ខ្លួនឡើយ។ ចំពោះការយោងទៅលើសេចក្តីថ្លែងការណ៍របស់សាក្សីដែលមានរហស្សនាម TCW 729 គឺជា "កំហុសឆ្គង" ដែលមិនគួរកើតមានពីសំណាក់ភាគីរបស់ចៅក្រម។

## ឃ. បញ្ហាដែលកើតឡើងម្តងហើយម្តងទៀតលើការតាំងសំណួរដេញដោលទៅកាន់សាក្សី

បន្ទាប់ពីមានការកើតឡើងស្រដៀងគ្នានូវការជំនាស់ជាច្រើនមក អង្គជំនុំជម្រះសាលាដំបូង បានក្រើនរម្លឹកដល់ភាគីទាំងអស់ឲ្យធ្វើការបញ្ជាក់ឲ្យច្បាស់ពីការសម្អាង (ដោយផ្តល់នូវបរិបទនៃសំណួររបស់ពួកគេ) នៅពេលដែលសួរសំណួរទៅកាន់សាក្សី។ ប្រការនេះ មានភាពសារៈសំខាន់ជាពិសេស នៅពេលដែលសំណួរបានយោងទៅតាមកាលបរិច្ឆេទ ឬអំឡុងពេលវេលាណាមួយ។ ការជំទាស់ជាច្រើនទៅនឹងសំណួរ

ដែលបានលេចឡើងនាសប្តាហ៍នេះ ត្រូវបានលើកឡើងដោយផ្អែកលើមូលដ្ឋានថា សំណួរទាំងនោះ ជាសំណួរដឹកមុខ ច្រំដែល ឬស្មាន។

## ផ្នែកទី ៤៖ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

មានដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ ៣០នាក់ បានចូលរួមតាមដានកិច្ចដំណើរការនីតិវិធីសវនាការជារៀងរាល់ថ្ងៃ ទាំងនៅក្នុងបន្ទប់សវនាការ ឬសាលសាធារណជន។ មេធាវីតំណាងឲ្យពួកគាត់ បានសួរដេញដោលទៅកាន់លោក **សាឡុត បាន** អំពីមនុស្សដែលបានបាត់ខ្លួន ត្រូវគេចាប់ខ្លួន ឬត្រូវគេសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ក៏បានសួរនាំអំពី បឹងត្របែក និងច្រាំងចំរេះផងដែរ។

មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ជេត វណ្ណលី** និងលោកស្រី **អេលីហ្សាបេត រ៉ាបេសាន់ដ្រាតាណា** (Ms. Elisabeth RABESANDARATANA) បានធ្វើការតាំងសំណួរដេញដោលទៅកាន់សាក្សីរូបនេះនៅអំឡុងពេលវគ្គពិភាក្សាដេញដោលពេលរសៀលនៅថ្ងៃពុធ។ សំណួរដេញដោលរបស់ពួកគាត់ ភាគច្រើនបានផ្តោតទៅលើការទាមទារជាក់លាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងប្រជាជនដែលតាមឲ្យដឹងមកបានបាត់ខ្លួន ឬត្រូវបានបញ្ជូនទៅកាន់ ស-២១។ ទោះបីជាយោងតាមការផ្តល់សក្ខីកម្មរបស់សាក្សីក៏ដោយ ក៏វាបានបង្ហាញថា គាត់មិនបានដឹងអំពីព័ត៌មានដែលមានតម្លៃជាទម្ងន់ ឆ្លើយតបទៅនឹងការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

បន្ថែមជាងនេះទៅទៀត មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បានសួរដេញដោលទៅកាន់លោក **សាឡុត បាន** អំពីស្ថានភាពនៃបញ្ញវន្តដែលបានត្រឡប់មកប្រទេសវិញ នៅបឹងត្របែក និងច្រាំងចំរេះ។ យ៉ាងចំៗនោះ មេធាវី បានសួរសាក្សីថាតើគាត់បានស្គាល់មន្រ្តីការទូតណាមួយនៅពេលនោះដែរឬទេ? គាត់បានទទួលស្គាល់ថា គាត់បានស្គាល់លោក **ហោ ណាំហុង** និងធ្លាប់បានឮឈ្មោះ លោក **ហួត សម្បត្តិ** និង **នរោត្តម ភូរីស្សារា** (ញាតិវង្សានុវង្សរបស់ព្រះករុណា ព្រះបាទសីហនុ)។ ក៏ប៉ុន្តែ គាត់មិនអាចផ្តល់នូវព័ត៌មានអ្វីបានច្រើនឡើយ។ នៅពេលដែលមានសំណួរសួរថាតើគាត់បានដឹងពីមនុស្សឈ្មោះ **ចៅ សេង** ដែរឬទេ? សាក្សីបាននិយាយថា ការយល់ដឹងរបស់គាត់មានកម្រិតត្រឹមតាមរយៈការតាមដានសារព័ត៌មាន ដែលបានរាយការណ៍ថា ឈ្មោះរបស់ **ចៅ សេង** បានប្តូរមកជា **ចិន សួន** វិញបន្ទាប់ពីត្រូវបានចាប់ខ្លួន។

ទាក់ទងនឹង អ្នកស្រី **ខៀវ ធីរ៉ាត់** លោក **សាឡុត បាន** បាននិយាយថា គាត់ធ្លាប់បានដឹងថា អ្នកស្រី **ខៀវ ធីរ៉ាត់** គឺជាបងស្រីរបស់អ្នកស្រី **អៀង ធីរិទ្ធ** ដែលជាបញ្ញាជន និងជាគ្រូបង្រៀនមកពីស្រុកបារាំង។ គាត់បានបង្ហើបប្រាប់ថា អ្នកស្រី **ខៀវ ធីរ៉ាត់** បានត្រូវគេសម្លាប់ដោយច្របាច់កនៅក្នុងការិយាល័យ ២១ នៅតាខ្មៅក្រោមការដឹកនាំរបស់ **ប៉ង់**។ លោក **សាឡុត បាន** ក៏បានទម្លាយឲ្យដឹងថា គាត់បាននាំយកសាកសពរបស់អ្នកស្រី **ខៀវ ធីរ៉ាត់** ដោយផ្ទាល់ទៅវត្តដើម្បីបូជាសព ក៏ប៉ុន្តែគាត់មិនបាននិយាយពីវិធីយ៉ាងម៉េចដែលបានជាគាត់អាចយកសាកសពរបស់អ្នកស្រី **ខៀវ ធីរ៉ាត់**។ គាត់បានបញ្ជាក់បន្ថែមថា ខណៈពេលដែលគ្មានការដាក់វិន័យណាមួយមកលើ **ប៉ង់** ក៏ប៉ុន្តែនៅក្រោយមក **ប៉ង់** បានបាត់ខ្លួន។ គាត់មិនបានដឹងថាតើការបាត់ខ្លួនរបស់ **ប៉ង់** មានជាប់ពាក់ព័ន្ធនឹងការស្លាប់របស់អ្នកស្រី **ខៀវ ធីរ៉ាត់** ដែរឬទេ?

មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី បានសាកសួរអំពីលោក **អ៊ិន សូកាន** លោក **ហ៊ឹង អ៊ុន** លោក **ជាម** (ដែលបានធ្វើការជាមួយលោក **សាឡុត បាន**) **តាជាង** និងប្រពន្ធគាត់ឈ្មោះ **សើ** (ជាមេចុងភៅនៅច្រាំងចំរេះមុនពេលដែលលោក **សាឡុត បាន** បានមកកាន់) លោក **ភឹង តុន** និងលោក **រស់ សារិន** (ដែលត្រូវបានចាប់ខ្លួនមកជាមួយនឹង **ភឹង តុន**)។ ប្រពន្ធរបស់លោក **រស់ សារិន**[15] និងញាតិសន្ដានរបស់ **ថៅ សេង**[16] គឺជាដើមបណ្ដឹងរដ្ឋប្បវេណី។ សាក្សីរូបនេះ ភាគច្រើនបាននិយាយថា គាត់មិនបានស្គាល់ពីពួកគេ ឬថា គាត់ធ្លាប់បានឮឈ្មោះ ក៏ប៉ុន្តែមិនបានស្គាល់ពួកគេដោយផ្ទាល់ឡើយ។ នៅពេលដែលមានសំណួរសួរពីទីកន្លែងណាដែលគាត់បានយកមនុស្សទាំងនេះទៅ លោក **សាឡុត បាន** បានឆ្លើយតបទៅវិញថា គាត់មិនបានយកពួកគេចេញទៅណាទេ ពីព្រោះ **ប៉ង់** ជាអ្នកដែលយកពួកគេចេញទៅ។ លោក **សាឡុត បាន** បានគូសបញ្ជាក់ថា គាត់មិនបានមានបន្ទុកក្នុងការជម្លៀសមនុស្សចេញនោះទេ ក៏ប៉ុន្តែគាត់បានជួយពួកគេនៅក្នុងការស្វែងរកសមាជិកក្រុមគ្រួសាររបស់ពួកគេ។ គាត់បាននិយាយពន្យល់ថា "គ្រួសារខ្ញុំក៏បាត់ដែរ បងប្អូនក៏បាត់ដែរ ខ្ញុំរាវរកក៏មិនឃើញដែរ ទៅឲ្យខ្ញុំទៅរាវរកគ្រួសារពីឯណាទៀតទៅដឹង?។"

## ផ្នែកទី ៥៖ ការគ្រប់គ្រងសវនាការ

លោកប្រធានអង្គជំនុំជម្រះ **និល ណុន** បានគ្រប់គ្រងកិច្ចដំណើរការនីតិវិធីសវនាការនាសប្ដាហ៍នេះក្នុងសភាពអត់ធ្មត់ និងនឹងធឹង ដោយបានសួរសំណួរបញ្ជាក់ជាច្រើននៅពេលដែលចាំបាច់ ហើយបានចាត់ចែងដោះស្រាយនូវស្ថានភាពចម្រូងចម្រាសគ្នាក្នុងសភាពរម្យទម។ នៅពេលដែលសាក្សីមិនបានឆ្លើយឲ្យចំនឹងសំណួរ ឬបាននិយាយបង្វែងប្រធានបទដោយបានលើកឡើងនូវការសម្អាងលើជំនឿសាសនា លោកប្រធានអង្គជំនុំជម្រះ បានក្រើនរម្លឹកគាត់ឲ្យឆ្លើយតបនឹងសំណួរកំពុងសួរនោះវិញ តែទោះបីជាយ៉ាងណាក៏ដោយ លោកប្រធានបានផ្ដល់នូវសេចក្ដីទុកចិត្តឲ្យសាក្សីថា អង្គជំនុំជម្រះ និងមេធាវីប្រឹក្សារបស់គាត់ បានកំពុងការពារសិទ្ធិរបស់គាត់។ ប្រការនេះបានធ្វើឲ្យសាក្សីមានភាពធូរស្រាលចំពោះការភ័យខ្លាចនឹងភាពដែលអាចកើតមានទាក់ទងនឹងការចោទប្រកាន់មកលើរូបគាត់ ហើយបានលើកទឹកចិត្តឲ្យគាត់ឆ្លើយនឹងសំណួររបស់ភាគី។ ជាការគួរឲ្យកត់សម្គាល់ អង្គជំនុំជម្រះបានរៀបចំចំពោះតម្រូវការបន្តបន្ទាប់របស់សាក្សី ដោយឲ្យមានជំនួយពីមេធាវីប្រឹក្សា ហើយបានតែងតាំងឲ្យមេធាវីម្នាក់ឲ្យជួយគាត់ ចាប់តាំងការចាប់ផ្ដើមនៃការផ្ដល់សាក្សីរបស់គាត់នាសប្ដាហ៍នេះ។

### ក. វត្តមាន

ជនជាប់ចោទទាំងអស់ បានមានវត្តមានពេញមួយសប្ដាហ៍នេះ។ ដូចដែលបានកើតឡើងជាសព្វមួយដង លោក **អៀង សារី** បានស្នើសុំចូលរួមតាមដានតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ បន្ទាប់ពីបានបញ្ចប់វគ្គកិច្ចពិភាក្សាដេញដោលដំបូង ហើយលោក **នួន ជា** ក៏បានធ្វើការស្នើសុំដូចគ្នាផងដែរ បន្ទាប់ពីបាបញ្ចប់វគ្គទីពីរ។ រីឯ លោក **ខៀវ សំផន** បានមានវត្តមានស្ដាប់គ្រប់កិច្ចដំណើរការនីតិវិធីពេញមួយសប្ដាហ៍នេះ។

វគ្គមានរបស់សាធារណជនៈ នៅថ្ងៃច័ន្ទ មានអ្នកភូមិប្រហែលជា ៤០០នាក់ មកពីខេត្តកំពង់ធំ បានចូលរួមតាមដានវគ្គកិច្ចពិភាក្សាដេញដោលពេលព្រឹក និងមានសិស្សានុសិស្សប្រមាណជា ៣០០នាក់ បានមកពីសាលាជ័យវរ្ម័នទី៧ ស្រុកកៀនស្វាយ ចូលរួមស្តាប់វគ្គកិច្ចពិភាក្សាដេញដោលពេលរសៀល។ នៅថ្ងៃអង្គារ អ្នកភូមិប្រហែលជា ៣០០នាក់ មកពីខេត្តព្រៃវែង បានចូលរួមតាមដានសវនាការនៅពេលព្រឹក។ ហើយមាននិស្សិតប្រមាណជា ៣០០នាក់ មកពីសាកលវិទ្យាល័យអាស៊ីអឺរ៉ុប បានសង្កេតតាមដាននៅវគ្គពេលរសៀល។ នៅថ្ងៃពុធ អ្នកភូមិជិត ៤០០នាក់ បានមកពីគន្ធៈបុប្ផា ស្រុកព្រៃឈរ ខេត្តកំពង់ចាម បានធ្វើដំណើរមកកាន់ **អ.វ.ត.ក** ដើម្បីធ្វើជាសក្ខីភាពនៃកិច្ចដំណើរការនីតិវិធីពេលព្រឹក។ ហើយនៅពេលរសៀល សិស្សានុសិស្សប្រហែលជា ២០០នាក់ មកពីសាលាមេគង្គកម្ពុជា បានចូលរួមស្តាប់កិច្ចពិភាក្សាដេញដោល។ ជាចុងក្រោយ នៅថ្ងៃព្រហស្បតិ៍ ដែលជាថ្ងៃចុងក្រោយនៃកិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ សិស្សានុសិស្សប្រមាណជា ២០០នាក់ មកពីវិទ្យាល័យក្រឡាញ់ បានចូលរួមស្តាប់វគ្គពិភាក្សាពេលព្រឹក ហើយមានអ្នកភូមិប្រហែលចំនួន ១៥០ មកពីខេត្តបាត់ដំបូង និងសៀមរាប ក៏ដូចជានិស្សិតជិត ៣០០នាក់ មកពីវិទ្យាស្ថានជាតិអប់រំ បានតាមដាននៅវគ្គរសៀល។ នៅពេញមួយសប្តាហ៍នេះ មានអ្នកសង្កេតការណ៍ឯករាជ្យ និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ក៏បានចូលរួមស្តាប់កិច្ចដំណើរការនីតិវិធីផងដែរ។

លោក **ឌឹម សុវណ្ណារុំ** ប្រធានអង្គភាពកិច្ចការសាធារណៈប្រចាំ **អ.វ.ត.ក** បានផ្តល់ការណែនាំដ៏គួរឲ្យចាប់អារម្មណ៍ ជាមួយនឹងព័ត៌មានលម្អិតស្តីពីស្ថានភាពជាក់ស្តែងនៃកិច្ចដំណើរការនីតិវិធី សាក្សីដែលផ្តល់សក្ខីកម្មនៅសប្តាហ៍នេះ ហើយនិងភាគីដែលនឹងធ្វើការតាំងសំណួរដេញដោល។

## ខ. បញ្ហាបច្ចេកទេស និងការបកប្រែភាសា

អង្គជំនុំជម្រះសាលាដំបូង បានមានបំណងតាំងពីដើមមកក្នុងការបិទបញ្ចប់ការស្តាប់សក្ខីកម្មរបស់លោក **សាឡុត បាន** នៅចុងសប្តាហ៍នេះ ដើម្បីឲ្យគាត់អាចវិលត្រឡប់ទៅកាន់ផ្ទះរបស់គាត់វិញនៅខេត្តរបស់គាត់។ ក៏ប៉ុន្តែ ប្រព័ន្ធសំឡេងដំណើរការមិនត្រឹមត្រូវ ហើយបានចំណាយពេលអស់ពេញមួយវគ្គកិច្ចពិភាក្សាដេញដោលនៅថ្ងៃអង្គារពេលព្រឹក។ ជាបច្ច័យមក អង្គជំនុំជម្រះ បានសម្រេចចិត្តបន្តការធ្វើសក្ខីកម្មរបស់លោក **សាឡុត បាន** នៅសប្តាហ៍បន្ទាប់។

មានបញ្ហាទាក់ទងនឹងការបកប្រែភាសា ក៏បានកើតឡើងផងដែរនៅពេញមួយសប្តាហ៍នេះ។ នៅថ្ងៃអង្គារ ខណៈពេលដែលលោក **វ៉ាយន៍** បានកំពុងសួរសំណួរដេញដោលទាក់ទងនឹងចម្លើយសារភាពរបស់លោក **កុយ ធួន** ហើយបានអានការដកស្រង់ចេញពីឯកសារដែលបានមកពីការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លោក **ផេស្តមិន** បានបញ្ជាក់ថា មានការបកប្រែខុសគ្នារវាងភាសាអង់គ្លេស និងភាសាបារាំង។ លោក **វ៉ាយន៍** បានអះអាងលើការផ្តល់មតិយោបល់របស់លោក **ផេស្តមិន** ។ ការបកប្រែភាសាខ្មែរ និងភាសាបារាំង បាននិយាយថា សាក្សីបានដឹងពីការឆ្លើយដាក់គ្នាប្រឆាំងនឹងបុគ្គលិកពីរនាក់របស់ក្រសួងការបរទេស រីឯភាសាអង់គ្លេសបាននិយាយថា សាក្សីមិនបានដឹងពីបញ្ហានេះឡើយ។ ជាងនេះទៅទៀត ចំនួនលេខ និងឆ្នាំ មានការភាន់ច្រឡំគ្នាជាពីរបីដងផងដែរ។

ជាការគួរឲ្យកត់សម្គាល់ នៅពេលណាក៏ដោយដែលមេធាវីខាងកម្ពុជា បាននាំមុខក្នុងការតាំងសំណួរដេញដោល ការបកប្រែភាសាបានជួបប្រទះនឹងបញ្ហាលំបាក ដោយសារការដកឃ្លារវាងការតាំងសំណួរដេញ

ដោល និងការផ្តល់ចម្លើយតប មានថេរវេលាខ្លីពេកក្នុងការធានាឲ្យការបកប្រែមានភាពពេញលេញ និងត្រឹមត្រូវ។ នៅថ្ងៃពុធ អ្នកបកប្រែភាសា មិនបានបកប្រែពីការស្នើសុំរបស់សាក្សីឲ្យធ្វើការអានសំណួរដេញដោលម្តងទៀត និងចម្លើយរបស់គាត់ដែលបាននិយាយថា គាត់មិនបានដឹង។ ដូចគ្នាផងដែរ នៅថ្ងៃពុធ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី **វ៉ាបេសាន់ជ្រាតាណា** មិនបានឮការបកប្រែពីការជំទាស់ដោយលោក **កាណាវ៉ាស** ហើយការជំទាស់នោះមិនបានលើកឡើងម្តងទៀតទេ និងមិនបានបកប្រែហើយលោកប្រធានអង្គជំនុំជម្រះ ក៏ពុំបានពន្យល់ទៅកាន់លោកស្រីមេធាវីពីការជំទាស់អ្វីដែលបានធ្វើឡើងនោះ ដែលប្រការនេះមានសារៈសំខាន់សម្រាប់អ្នកស្រីមេធាវីក្នុងករណីគាត់គួរផ្លាស់ប្តូរកម្រិតពាក្យពេចន៍នៃការតាំងសំណួររបស់គាត់។

## គ. ការគ្រប់គ្រងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ២៣/០៤/១២ | ៩:០៣ | ១០:៣៣-១០:៥៣ | ១២:០១-១៣:៣១ | ១៤:៤១-១៥:០១ | ១៦:០២ | ៤ម៉ោង និង៤៩ នាទី |
| ថ្ងៃអង្គារ ២៤/០៤/១២ | ៩:០១ | ១០:៣៣-១០:៥៤ | ១១:១០-១៣:៣០ | ១៤:៥២-១៥:១១ | ១៦:១៦ | ៤ម៉ោង និង១៥ នាទី |
| ថ្ងៃពុធ ២៥/០៤/១២ | ៩:០១ | ១០:៣៨-១០:៥៩ | ១២:០៧-១៣:៣១ | ១៤:៤០-១៥:០២ | ១៦:១៨ | ៥ម៉ោង និង១០ នាទី |
| ថ្ងៃព្រហស្បតិ៍ ២៦/០៤/១២ | ៩:០២ | ១០:៤៦-១១:១១ | ១២:០៣-១៣:៣១ | ១៤:៤៤-១៥:០៤ | ១៦:០៧ | ៤ម៉ោងនិង៥២ នាទី |
| *រយៈពេលសវនាការជាមធ្យម* | | | | *៤ម៉ោង និង៤៦នាទី* | | |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | | | | *១៩ម៉ោង និង៦នាទី* | | |
| *ចំនួនម៉ោង ថ្ងៃ និងសប្តាហ៍នៃសវនាការ* | | | | *២៤៤ម៉ោង និង៣២នាទី* | | |
| ***រយៈពេលសវនាការចំនួន ៥៦ថ្ងៃ អំឡុងពេល ១៦សប្តាហ៍*** | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

* This issue of KRT Trial Monitor was authored by Mary Kristerie A. Baleva, Nora Fuchs, Faith Suzzette D. Kong,Noyel Ry, Kimsan Soy, Chayanich Thamparipattra and Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT Trial Monitor reports on Case 002 are available at <www.krtmonitor.org>, <http://forum.eastwestcenter.org/Khmer-Rouge-Trials/> and <http://socrates.berkeley.edu/~warcrime/>. AIJI is a collaborative project between the East-West Center, in Honolulu, and the University of California, Berkeley War Crimes Studies Center. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open

Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

[1] Witness was questioned first by Prosecutors Dararasmey Chan and Vincent de Wilde; followed by Civil Party's Lawyers Chet Vanly and Elisabeth-Joelle Rabesandratana; by President Nil Nonn and Judge Lavergne; and, lastly, by Ieng Sary's international counsel, Mr. Michael Karnavas.

[2] See Closing Order. Para.1097-1100. 278-279.

[3] According to Duch, Sua Va Sy was the Chairman of Political Office 870. See Asian International JusticeInitiative. KRT Trial Monitor [hereinafter, CASE 002 KRT TRIAL MONITOR] Issue No. 16, Hearing on Evidence Week
11 (26-29 March 2012). 3.

[4] According to Nuon Chea, Office 100 was located in Rattanakiri between 1968-1970. See CASE 002 KRT TRIAL MONITOR. Issue No. 8, Hearing on Evidence Week 3 (10-12 January 2012). 4.

[5] For more information on the alleged roles of Doeun and Pang in Office 870, see OCIJ. "Closing Order". (15September 2010). D427 [hereinafter, CLOSING ORDER] para. 48-61.

[6] In Khieu Samphan's comments during the Opening Statements, he denied that he was the head of Office 870. See CASE 002 KRT TRIAL MONITOR. Issue No. 5, Opening Statements (21-23 November 2012). 9.

[7] According to Duch, Yun Yat, alias "Comrade At" was in-charge of Internal and External Propaganda and Re-education. See CASE 002 KRT TRIAL MONITOR. Issue No. 16, Hearing on Evidence Week 11 (26-29 March 2012).3.

[8] On Thursday afternoon, 26 April 2012, Witness told Karnavas that Pang used to call him through landline telephone to instruct Witness to allow Pang's subordinates to pick up personnel of the MFA.

[9] Based on paragraph 55 of the Closing Order, K-1 "was a housing compound containing both the residence and working place of Pol Pot, though some witnesses state that K-1 was only the working place of Pol Pot. Furthermore, a number of witnesses state that Nuon Chea and Khieu Samphan would also reside and/or work at times with Pol Pot at K-1."

[10]Later during the week, particularly on Thursday, 26 April 2012, Karnavas asked Saloth Ban to clarify what he meant by "Case 000." Witness explained that a person cannot reach number 10, 100, and so forth, without starting from 0.

[11]CASE 002 KRT TRIAL MONITOR. Issue No. 15, Hearing on Evidence Week (19-21 March 2012). 9.

[12] CASE 002 KRT TRIAL MONITOR, Issue No. 19 (18-20 April 2012).

[13]Rule 24.1 states, " Before being interviewed by the Co-Investigating Judges or testifying before the Chambers, witness shall take an oath or affirmation in accordance with their religion or beliefs to state the truth." In Cambodian criminal procedure, a witness is required to take an oath before "The Iron God" or, in Khmer, "Nak Ta Dambang Dek", who would punish those who lied.

[14] Trial Chamber. Transcript of Hearing (24 January 2012).E1/32.1. (hereinafter, "24 January Transcript). 45.Lines 16-21.

[15] In its Judgment in Case 001, the Trial Chamber recognized Ms. Ros Chuor Siy, the wife of Mr. Ros Sarin as a Civil Party for the loss of her husband. See Case 001. Trial Chamber. "Judgement" (26 July 2010). E188. Par. 650. 231

[16] Ros Sarin was a former GRUNK official. See, Case001. Trial Chamber. "Transcript of Proceedings" (19 August 2009). D288/4.65.1 CF001. 73-74; Written Record of Interview of Civil Party. D368/2. 4.